Food and Agriculture Organization of the United Nations

This programme is co-funded by the European Union




# របាយការណ៍ ស្ថិតិផលនេសាទទឹកសាប ប្រចាំឆ្នាំ២០២២

## របាយការណ៍ស្ថិតិ ស្តីពីការវាយតម្លៃផលនេសាទទឹកសាបក្នុងប្រទេសកម្ពុជា

**ខែមេសា ឆ្នាំ ២០២៣**

ចងក្រងដោយ៖ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប

*ការបោះពុម្ពផ្សាយនេះទទួលបានការគាំទ្រហិរញ្ញវត្ថុពីសហភាពអឺរ៉ុប។ ខ្លឹមសារនៅក្នុងឯកសារនេះ ជាការទទួលខុសត្រូវរបស់រដ្ឋបាលជលផល ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។*

# សេចក្ដីថ្លែងអំណរគុណ

របាយការណ៍ស្ថិតិ ស្ដីពីការវាយតម្លៃផលនេសាទទឹកសាបក្នុងប្រទេសកម្ពុជាប្រចាំឆ្នាំនេះ ត្រូវបានរៀបចំឡើងក្រោមជំនួយហិរញ្ញវត្ថុពីសហភាពអឺរ៉ុប របស់កម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្ន ដោយមានជំនួយបច្ចេកទេសពី អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) ដែលមានការសហការយ៉ាងជិតស្និទ្ធជាមួយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប។ សូមថ្លែងអំណរគុណជាពិសេសចំពោះ **លោកបណ្ឌិត ហេង គង់** ប្រធានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាប **លោក ចាយ គង់គ្រុយ** អនុប្រធានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាបដែលបានផ្ដល់ការណែនាំទូទៅ និងមតិយោបល់ល្អៗលើសេចក្ដីព្រាងចុងក្រោយ និង**លោក សូត្រ សុបុត្រ** ដែលបានរៀបចំ និងវិភាគទិន្នន័យស្ថិតិប្រចាំខែ សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំរបាយការណ៍ប្រចាំឆ្នាំនេះ។ ការវិភាគទិន្នន័យ មានការគាំទ្រផ្នែកបច្ចេកទេសជាបន្តបន្ទាប់ពី **លោក Theo Visser** (មន្ត្រីគ្រប់គ្រងជលផលទឹកសាបនៃអង្គការ FAO) និង **លោក សូ ដាណេ** (អ្នកឯកទេសមូលដ្ឋានទិន្នន័យនៃអង្គការ FAO) និង **លោក អ៊ុន បូរិន** (អ្នកឯកទេសស្រាវជ្រាវជលផលនៃអង្គការ FAO)។

## ចងក្រងដោយ

**បណ្ឌិត ហេង គង់ លោក សូត្រ សុបុត្រ និងលោក ចាយ គង់គ្រុយ**

ដោយមានជំនួយបច្ចេកទេសពីគម្រោង FAO CAPFISH

## គុណកថាបង្អែក

រដ្ឋបាលជលផល (២០២១). របាយការណ៍ស្ថិតិ ស្ដីពីការវាយតម្លៃផលនេសាទទឹកសាបក្នុងប្រទេសកម្ពុជា វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាបនៃរដ្ឋបាលជលផល, រាជធានីភ្នំពេញ ប្រទេសកម្ពុជា ២៥ទំព័រ។

## ទំនាក់ទំនង

រដ្ឋបាលជលផល
វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប
#១៨៦ មហាវិថីនរោត្ដម រាជធានីភ្នំពេញ ប្រទេសកម្ពុជា

© រដ្ឋបាលជលផល
រក្សាសិទ្ធគ្រប់យ៉ាង។ ការបោះពុម្ពឡើងវិញទាំងស្រុង ឬផ្នែកណាមួយសម្រាប់គោលបំណងអប់រំ ឬមិនរកប្រាក់ចំណេញ មិនតម្រូវឱ្យសុំការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិបញ្ញាឡើយ ដោយគ្រាន់តែថ្លែងអំណរគុណដល់ប្រភពដើម។ រាល់ការបោះពុម្ព ការចម្លង ឬចែកចាយសម្រាប់លក់បន្ត ឬគោលបំណងពាណិជ្ជកម្មផ្សេងទៀតត្រូវសុំការអនុញ្ញាតពីរដ្ឋបាលជលផល។
រាល់មតិយោបល់ និងមតិដែលបានបង្ហាញនៅទីនេះ គឺជាមតិរបស់អ្នកនិពន្ធ ហើយមិនអាចឆ្លុះបញ្ចាំងពីជំហររបស់រដ្ឋបាលជលផល ដៃគូ ឬអង្គការ ដែលផ្ដល់មូលនិធិសម្រាប់គម្រោ ងនិងការបោះពុម្ពផ្សាយនោះទេ។

# សេចក្តីសង្ខេប

ការសម្ភាសវាយតម្លៃផលនេសាទតាមបែបវិទ្យាសាស្ត្រ ត្រូវបានអនុវត្តរយៈពេល៩ខែ ក្នុងឆ្នាំ២០២២ ដោយមន្ត្រីនៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប និងមន្ត្រីខណ្ឌរដ្ឋបាលជលផលតាមបណ្តាខេត្តគោលដៅ។ ការសម្ភាសបានគ្របដណ្តប់ជាមធ្យម ២៥ភូមិ និង៣៥០គ្រួសារអ្នកនេសាទជារៀងរាល់ខែ នៅតាមតំបន់នេសាទសំខាន់ៗចំនួនបី គឺតំបន់ទន្លេសាប វាលទំនាបលិចទឹក និងតំបន់ខ្ពង់រាប។

ការតាមដានបម្រែបម្រួលផលនេសាទតាមរដូវ និងនៅតាមតំបន់នេសាទនានាក៏បានអនុវត្តផងដែរ ដូចជាការតាមដានលើគ្រួសារអ្នកនេសាទដែលចេញនេសាទតិចតួច និងចំនួនថ្ងៃធ្វើនេសាទនៅរដូវប្រាំង។ ផលនេសាទប្រចាំខែតាមគ្រួសារនីមួយៗខ្ពស់បំផុតមាននៅតំបន់បឹងទន្លេសាប បន្ទាប់មក គឺការនេសាទតាមដងទន្លេមេគង្គ និងតំបន់ទំនាបលិចទឹក។ ផលនេសាទសរុបមានចំនួន ៣៦៨.០០០តោន ដោយមិនរាប់បញ្ចូលខេត្តតំបន់ភ្នំ និងតំបន់ឆ្នេរ ដែលក្នុងនោះតំបន់នេសាទដែលបានរួមចំណែកដល់ផលនេសាទខ្ពស់ជាងគេ គឺតំបន់បឹងទន្លេសាប (៤៩,៥%) តំបន់ទំនាបលិចទឹក (៤២,២%) ហើយផលនេសាទនៅសល់ គឺតំបន់ខ្ពង់រាប។

បុរសពេញវ័យភាគច្រើនចូលរួមក្នុងសកម្មភាពនេសាទ(៩១,៥%) និងស្ត្រីពេញវ័យ (៩,៣%)។ ផលនេសាទភាគច្រើនត្រូវបានចាប់ដោយមិនប្រើប្រាស់ទូកនេសាទ (៥២,៣%) ដោយឡែកទូកប្រើម៉ាស៊ីនរួមចំណែកត្រឹមតែ ៣៤,៤% នៃផលនេសាទរាយការណ៍សរុប។ សមាមាត្រនេះ គឺខ្ពស់បំផុតសម្រាប់គ្រួសារនេសាទនៅតំបន់ខ្ពង់រាប។ ផលនេសាទភាគច្រើន គឺនេសាទបានពីជម្រកទំនាបលិចទឹក (៣៣,១%) បន្ទាប់មក គឺការនេសាទតាមដងទន្លេមេគង្គ (១៩,៣%) និងដៃទន្លេនានា (១០,៤%)។ ជារួមឧបករណ៍នេសាទសំខាន់បំផុត និងមានរួមចំណែកច្រើនជាងគេ គឺមង (៤៥,១%) លប (១៧,៦%) សំណាញ់ (១១,២%) និងការចាប់ដោយដៃ (៨,៤%) មងកាំង (៣៥,៦%) ហើយប្រភេទមងដែលមានការធ្វើនេសាទច្រើនជាងមងបណ្តែត (៩,៥%)។

ផលនេសាទ ៤៦,៩% គឺត្រូវបានគេលក់ និង៣៤,៤% គឺត្រូវបានគេប្រើប្រាស់សម្រាប់បរិភោគ ហើយសម្រាប់ការប្រើប្រាស់ផ្សេងទៀតមានប្រមាណ ១៨,៧%។ ក្នុងនោះតំបន់ទំនាបលិចទឹកមានការលក់ផលនេសាទខ្ពស់ជាងគេ ប្រមាណ ៥៤,៨% និងតំបន់ទន្លេសាបប្រមាណ ៤៧,៩% និង៣៥,៧% នៅតំបន់ខ្ពង់រាបដែលមានការលក់ផលនេសាទទាបបំផុត។ ការលក់ផលនេសាទ គឺមានភាពការប្រែប្រួលតាមរដូវ ដោយការលក់ផលនេសាទនេះជាទូទៅខ្ពស់នៅរដូវប្រាំងនៅតំបន់ទំនាបលិចទឹក និងតំបន់ទន្លេសាប។

ត្រីរួមចំណែក ៨៦,៥% នៃផលនេសាទសរុបរបស់ប្រជានេសាទ និងវារីសត្វផ្សេងៗទៀត (OAA) រួមចំណែកប្រមាណ ១៣,៥% ដែលក្នុងនោះផលនេសាទវារីសត្វចាប់បានច្រើននៅក្នុងរដូវប្រាំង។ មានប្រភេទត្រីចំនួន ២០ប្រភេទ ដែលនេសាទបានច្រើនជាងគេ (បរិមាណ) និងបានរួមចំណែក ៦៩% នៃផលនេសាទសរុប ក្នុងនោះប្រភេទត្រីរ៉ស់/ផ្ទក់ (*Channa striata*) ប្រភេទត្រីក្រាញ់ (*Anabas testudineus*) និងប្រភេទត្រីរៀលអង្កាម (*Henicorhynchus lobatus*) ជាប្រភេទដែលនេសាទបានខ្ពស់បំផុតដែលមានប្រមាណ ២២,៧% នៃផលនេសាទសរុប។ ភាពចម្រុះនៃប្រភេទត្រីច្រើនបំផុតមាននៅអំឡុងខែសីហា និងខែតុលា។

របាយការណ៍នេះបានបញ្ចូលនូវអនុសាសន៍មួយចំនួនសម្រាប់អនុវត្តការវាយតម្លៃផលនេសាទក្នុងកំឡុងឆ្នាំ ២០២៣ ដើម្បីទទួលបាននូវលទ្ធផលកាន់តែមានភាពល្អប្រសើរទូទាំងប្រទេសកម្ពុជា ក៏ដូចជាផលនេសាទសរុបតាមបណ្តាខេត្តគោលដៅនីមួយៗផងដែរ។

# មាតិកា

សេចក្តីថ្លែងអំណរគុណ ........................................ 2
សេចក្តីសង្ខេប ........................................ 3
តារាងពាក្យបំព្រួញ........................................ 5
១. សេចក្តីផ្តើមនិងវិធីសាស្ត្រស្រាវជ្រាវ ........................................ 7
២. តារាងស្ថិតិនិងលទ្ធផល ........................................ 7
៣. ការពិភាក្សានិងអនុសាសន៍ ........................................23

# តារាងពាក្យបំព្រួញ

| | | |
|---|---|---|
| AP | Aquatic Plants | រុក្ខជាតិវារីវប្បកម្ម |
| CAPFISH | Cambodia Programme for Sustainable and Inclusive Growth in the Fisheries Sector | កម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាពនិងបរិយាប័ន្នៈសមាសភាគការនេសាទ |
| CAS | Catch Assessment Survey | ការសម្ភាសវាយតម្លៃផលនេសាទ |
| CPUE | Catch per Unit of Effort | សមត្ថភាពចាប់ក្នុងមួយខ្នាតឯកត្តា |
| CWP | Coordinating Working Party | ភាគីសម្របសម្រួលការងារ |
| DFMP | Dai Fisheries Monitoring Programme | កម្មវិធីតាមដានផលចាប់ដាយឧបករណ៍ដាយ |
| DPFIC | Department of Planning, Finance and International Cooperation | នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងសហប្រតិបត្តិការអន្តរជាតិ |
| EU | European Union | សហភាពអឺរ៉ុប |
| ε% | Relative Standard Error | កំហុសស្តង់ដារទាក់ទង |
| FAO | Food and Agriculture Organisation | អង្គការស្បៀងនិងកសិកម្ម |
| FH | Fishing Household | គ្រួសារអ្នកនេសាទ |
| FiA | Fisheries Administration | រដ្ឋបាលជលផល |
| FiAC | Fisheries Administration Cantonment | ខណ្ឌរដ្ឋបាលជលផល |
| GIS | Geographic Information System | ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ |
| HCI | Household Catch Interview | ការសម្ភាសផលចាប់តាមគ្រួសារ |
| HH | Household | គ្រួសារ |
| HSI | Household Selection Interview | ការជ្រើសរើសគ្រួសារសម្រាប់ធ្វើសម្ភាស |
| IFReDI | Inland Fisheries Research and Development Institute | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

| | | |
|---|---|---|
| MRC | Mekong River Commission | គណៈកម្មការទន្លេមេគង្គ |
| MT | Metric Ton | មួយតោន (១០០០គីឡូក្រាម) |
| NA | Not Applicable | គ្មានព័ត៌មាន |
| nei | not elsewhere included | គ្មានក្នុងក្រុមដទៃ |
| NF | Non-fish (for species codes) | មិនមែនត្រី (កូដសម្គាល់ប្រភេទ) |
| NIS | National Institute for Statistics | វិទ្យាស្ថានជាតិស្ថិតិ |
| OAA | Other Aquatic Animals | វារីសត្វដទៃទៀត |
| OAO | Other Aquatic Organisms | វារីសារពាង្គកាយដទៃទៀត |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| SES | Socio-Economic Survey | ការអង្កេតសេដ្ឋកិច្ចសង្គម |
| USD | United States Dollars | ដុល្លារអាមេរិក |
| WSIM | Working Group on Statistics and Information Management | ក្រុមការងារគ្រប់គ្រងស្ថិតិនិងព័ត៌មាន |

# ១. សេចក្តីផ្តើម និងវិធីសាស្ត្រស្រាវជ្រាវ

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប (IFReDI)ក្រោមជំនួយបច្ចេកទេសពីអង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) នៃកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈការគាំទ្រថវិការបស់សហភាពអឺរ៉ុប (EU) កំពុងអនុវត្តការវាយតម្លៃផលនេសាទតាមបែបវិទ្យាសាស្ត្រ ដោយប្រើប្រាស់វិធីសាស្ត្រសម្ភាសតាមបែបរំលឹកឡើងវិញជាមួយគ្រួសារនេសាទប្រចាំខែ។ គោលបំណងនៃការវាយតម្លៃនេះ គឺដើម្បីទទួលបានព័ត៌មានកាន់តែប្រសើរអំពីផលនេសាទ និងសមត្ថភាពនេសាទ ដោយគ្រួសារអ្នកនេសាទខ្នាតតូចក្នុងប្រទេសកម្ពុជា និងបង្កើតអោយមានវិធីសាស្ត្រតាមដានវាយតម្លៃផលនេសាទមួយប្រកបដោយនិរន្តរភាព សម្រាប់រដ្ឋបាលជលផលថ្នាក់ខេត្តអនុវត្ត ដោយមានការគាំទ្របច្ចេកទេសពី IFReDI។

ការប្រមូលទិន្នន័យនៅឆ្នាំ២០២២ បានធ្វើឡើងចាប់ពីខែមេសា ដល់ខែធ្នូ ឆ្នាំ២០២២ ហើយខ្លឹមសារនៃរបាយការណ៍ប្រចាំឆ្នាំនេះ គឺផ្អែកលើលទ្ធផលពីការប្រមូលទិន្នន័យរៀងរាល់ខែ របស់ក្រុមការងារស្រាវជ្រាវរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប និងមន្ត្រីខណ្ឌរដ្ឋបាលជលផលតាមបណ្តាខេត្តគោលដៅ។ របាយការណ៍ស្ថិតិនេះ បង្ហាញពីទិន្នន័យតាមតំបន់នេសាទ ដែលការបែងចែកនេះមានលក្ខណៈខុសប្លែកពីការបែងចែកតំបន់នេសាទរបស់អធិការដ្ឋាននៃរដ្ឋបាលជលផល។ ការបែងចែកខេត្តតាមតំបន់នេសាទនេះ គឺផ្អែកលើចំនួនសរុបនៃគ្រួសារនេសាទនៅទីជនបទ (ជំរឿនប្រជាជនឆ្នាំ២០១៩) និងសមាមាត្រនៃគ្រួសារនេសាទដែលទទួលបានពីការសម្ភាសជ្រើសរើសគ្រួសារនេសាទ (HSI)។ ការបែងចែកខេត្តតាមតំបន់នេសាទ ជាមួយនឹងចំនួនគ្រួសារ មានបង្ហាញជូនក្នុងឧបសម្ព័ន្ធ១។

ការពិពណ៌នាអំពីវិធីសាស្ត្រនៃការប្រមូល និងវិភាគទិន្នន័យផលនេសាទទឹកសាបអាចរកបានតាមរយៈ រដ្ឋបាលជលផល (FiA) ឆ្នាំ២០២១៖ ឯកសារណែនាំការវាយតម្លៃផលនេសាទទឹកសាបតាមបែបវិទ្យាសាស្ត្រក្នុងប្រទេសកម្ពុជា ប្រើការសម្ភាសតាមបែបរំលឹកឡើងវិញ ចងក្រងដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាបនៃរដ្ឋបាលជលផល រាជធានីភ្នំពេញ ប្រទេសកម្ពុជា ៤៧ទំព័រ។



សំណាកភូមិគោលដៅដែលបានជ្រើសរើសដោយចៃដន្យ នៅក្នុងអំឡុងពេលនៃការប្រមូលទិន្នន័យអនុវត្តចាប់ពីខែមេសា ដល់ខែធ្នូ ឆ្នាំ២០២២ នេះ គឺមានការប្រែប្រួល (តារាងទី១) ក្នុងនោះការប្រមូលទិន្នន័យពីខេត្តជាប់មាត់សមុទ្រ គឺមិនបានអនុវត្តបន្តនៅក្រោយខែឧសភា ឆ្នាំ២០២២។ ការប្រមូលទិន្នន័យបានរក្សាស្ថេរភាពសំណាកគោលដៅប្រមាណ ៣៦០គ្រួសារអ្នកនេសាទ រហូតដល់ចុងឆ្នាំ២០២២ ដែលបានធ្វើអោយការសម្ភាសគ្របដណ្តប់បានជាង ៩០% នៃគ្រួសារគោលដៅ។ ហេតុផលចម្បង ដែលនាំមិនអាចអនុវត្តបាន ១០០% លើសំណាកគំរូ គឺការមិនអាចរកឃើញគ្រួសារគោលដៅក្នុងអំឡុងពេលនៃការសម្ភាស។

**តារាងទី១**. ភូមិ និងសំណាកគ្រួសារ រួមនឹងសមាមាត្រនៃគ្រួសារគោលដៅនៅតាមតំបន់នេសាទ ចាប់ពីខែមេសា ដល់ខែធ្នូ ឆ្នាំ២០២២

| តំបន់នេសាទ | ភូមិ | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ឆ្នេរ | ២ | ៣ | | | | | | | |
| ទំនាបលិចទឹក | ១៣ | ១៧ | ១០ | ៨ | ៨ | ៨ | ៨ | ៨ | ៨ |
| ខ្ពង់រាប | ៤ | ៦ | ៧ | ៨ | ៧ | ៧ | ៧ | ៧ | ៧ |
| ទន្លេសាប | ១២ | ២៣ | ១០ | ១០ | ១០ | ១០ | ៩ | ៩ | ៩ |
| **សរុប** | **៣១** | **៤៩** | **២៧** | **២៦** | **២៥** | **២៥** | **២៤** | **២៤** | **២៤** |

| តំបន់នេសាទ | ចំនួនគ្រួសារ | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ឆ្នេរ | ៣០ | ៤៥ | | | | | | | |
| ទំនាបលិចទឹក | ១៨៥ | ២៦៦ | ១៤១ | ១២០ | ៩៩ | ១២០ | ១១០ | ១២១ | ១១២ |
| ខ្ពង់រាប | ៥៦ | ៩៤ | ៩៥ | ១០២ | ១០៥ | ១០៥ | ១០៥ | ១០៥ | ១០៥ |
| ទន្លេសាប | ១៤៩ | ៣២៨ | ១៤១ | ១៤២ | ១៤៤ | ១៤៦ | ១២៣ | ១២១ | ១២២ |
| **សរុប** | **៤២០** | **៧៣៣** | **៣៧៧** | **៣៦៤** | **៣៤៨** | **៣៧១** | **៣៣៨** | **៣៤៧** | **៣៣៩** |

| តំបន់នេសាទ | គ្រួសារគោលដៅសម្រាប់សម្ភាស (%) | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ឆ្នេរ | ១០០,០% | ១០០,០% | | | | | | | |
| ទំនាបលិចទឹក | ៩៤,៩% | ១០០,០% | ៩៤,០% | ១០០,០% | ៨២,៥% | ១០០,០% | ៩១,៧% | ១០០,០% | ៩៣,៣% |
| ខ្ពង់រាប | ៩៣,៣% | ១០០,០% | ៩០,៥% | ៨៥,០% | ១០០,០% | ១០០,០% | ១០០,០% | ១០០,០% | ១០០,០% |
| ទន្លេសាប | ៨២,៨% | ៩៥,១% | ៩៤,០% | ៩៤,៧% | ៩៦,០% | ៩៧,៣% | ៩១,១% | ៨៩,៦% | ៩០,៤% |
| **សរុប** | ៩០,៣% | ៩៩,៧% | ៩៣,១% | ៩៣,៣% | ៩២,៨% | ៩៨,៩% | ៩៣,៩% | ៩៦,៤% | ៩៤,២% |




**រូបភាពទី១.** ភូមិគោលដៅដែលត្រូវបានជ្រើសរើសដោយចៃដន្យសម្រាប់ CAS ក្នុងអំឡុងឆ្នាំ២០២២

សំណាកគំរូចៃដន្យដែលបានជ្រើសរើសសម្រាប់ការអនុវត្តក្នុងការវាយតម្លៃផលនេសាទទឹកសាប (CAS) ក្នុងអំឡុងឆ្នាំ២០២២ គឺបង្ហាញជូននៅក្នុងរូបភាពទី១។ ចំណុចក្រហម (CAS villages partial) បង្ហាញពីភូមិ ដែលត្រូវបានដកចេញពីសំណាកគោលដៅ នៅដើមគ្រានៃការអនុវត្ត CAS ដោយការប្រមូលទិន្នន័យឆ្នាំ២០២២ បានគ្របដណ្តប់តែផ្នែកខ្លះប៉ុណ្ណោះ។ CAS មិនបានគ្របដណ្តប់ខេត្តនៅតំបន់ភ្នំទេ ដោយសារតែរដូវកាលនៃសកម្មភាពនេសាទ និងធនធាន (ថវិកា) ដែលមានកំណត់សម្រាប់ការអនុវត្តការសម្ភាស។

ភាពខុសគ្នាតាមរដូវកាលសម្រាប់គ្រួសារអ្នកនេសាទដែលបានធ្វើនេសាទ និងចំនួនមធ្យមនៃផលនេសាទប្រចាំថ្ងៃមានបង្ហាញនៅក្នុងតារាងទី២ ក្នុងនោះផលនេសាទប្រចាំថ្ងៃខ្ពស់បំផុតនៅគ្រប់តំបន់នេសាទទាំងអស់ គឺនៅក្នុងខែមេសា ដល់ខែមិថុនា លើកលែងតែនៅតំបន់បឹងទន្លេសាប។ កម្រិតលំអៀងស្តង់ដារសមស្រប សម្រាប់ការប៉ាន់ប្រមាណផលនេសាទជាមធ្យមប្រចាំថ្ងៃ គឺមានតម្លៃទាបជាង ២០% ដែលតម្លៃនេះបង្ហាញពីភាពត្រឹមត្រូវតាមបែបស្ថិតិ និងបង្ហាញថាសំណាកមានទំហំសមល្មម សម្រាប់ធ្វើការសម្ភាសប្រមូលទិន្នន័យ។

លទ្ធផលដែលបានបញ្ចូលនៅក្នុងរបាយការណ៍ស្ថិតិប្រចាំខែបានបង្ហាញនូវតម្លៃខ្ពស់ជាងបន្តិចសម្រាប់កម្រិតលំអៀងស្តង់ដារសមស្រប និងមាននិន្នាការរក្សាបាននូវកម្រិតទាបជាង ២៥% ប៉ុន្តែមានករណីលើកលែងមួយចំនួនសម្រាប់តំបន់ទំនាបលិចទឹក នៅខែមេសា និងខែកក្កដា ដែលមានតម្លៃរហូតដល់ ២៧,៥% ដែលតម្លៃនេះតម្រូវអោយបង្កើនទំហំសំណាកខ្ពស់ជាងនេះបន្តិច[1]។

[1] តាមការប៉ាន់ប្រមាណការបង្កើនទំហំសំណាក ២០% នឹងនាំអោយ ៩% មានកម្រិតទាបជាង ២៥% គ្រប់ខែនិងតំបន់នេសាទទាំងអស់ ប៉ុន្តែវាតម្រូវអោយបង្កើនទំហំសំណាកស្ទើរតែទ្វេដង (៨៩% កើនឡើង) ដើម្បីធានាថា ៩% សម្រាប់តំបន់ទំនាបលិចទឹកតែងតែស្ថិតនៅក្រោម ២០% គ្រប់ខែទាំងអស់។

**តារាងទី២.** គ្រួសារអ្នកនេសាទសកម្ម ថ្ងៃធ្វើនេសាទប្រចាំខែ និងផលនេសាទតាមគ្រួសារ(គ.ក្រ) **ប្រចាំថ្ងៃ** ចំនួនមធ្យមជាមួយនឹងកម្រិតលំអៀងស្តង់ដារសមស្រប តាមត្រីមាស និងតាមតំបន់នេសាទ

| តំបន់នេសាទ | គ្រួសារសកម្ម | | ចំនួនថ្ងៃនេសាទប្រចាំខែ | ផលនេសាទតាមគ្រួសារ ប្រចាំថ្ងៃ (គ.ក្រ) | SD | ε% | ផលនេសាទតាមគ្រួសារប្រចាំខែ (គ.ក្រ) |
|---|---|---|---|---|---|---|---|
| | ចំនួន | % | | | | | |
| **មេសា-ឧសភា** | | | | | | | |
| ឆ្មេរ | ៣១ | ៤១,៣% | ៧,២ | ២,៨៥ | ២,៩៩ | ១៨,៨% | ២០,៦ |
| ទំនាបលិចទឹក | ២០១ | ៣៤,០% | ៥,១ | ៤,៧១ | ៨,១៧ | ១២,៣% | ២៤,១ |
| ខ្ពង់រាប | ៨០ | ៣២,៧% | ៦,២ | ៣,១០ | ២,៥៤ | ៩,២% | ១៩,៣ |
| ទន្លេសាប | ២៩៧ | ៤៨,១% | ៧,៥ | ៣,៩៦ | ៤,៣៥ | ៦,៤% | ២៩,៨ |
| សរុបរួម | ៦០៩ | ៣៩,៨% | ៦,៤ | ៤,០៤ | ៥,៧៣ | ៥,៨% | ២៥,៧ |
| **កក្កដា-កញ្ញា** | | | | | | | |
| ទំនាបលិចទឹក | ១៥២ | ៤៤,៨% | ៦,៧ | ២,២៦ | ២,៨៨ | ១០,៣% | ១៥,១ |
| ខ្ពង់រាប | ១៩៧ | ៦៣,១% | ១៤,០ | ២,២៤ | ៣,០២ | ៩,៦% | ៣១,៤ |
| ទន្លេសាប | ២៨៩ | ៦៦,៩% | ៩,៩ | ៣,០៥ | ៣,៦៨ | ៧,១% | ៣០,២ |
| សរុបរួម | ៦៣៨ | ៥៨,៩% | ១០,១ | ២,៦១ | ៣,៣២ | ៥,០% | ២៦,៣ |
| **តុលា-ធ្នូ** | | | | | | | |
| ទំនាបលិចទឹក | ១៨០ | ៥២,៥% | ៨,៥ | ២,៥៩ | ៣,៤៥ | ៩,៩% | ២២,១ |
| ខ្ពង់រាប | ១៦៤ | ៥២,១% | ១០,៧ | ២,៤៣ | ២,៦៣ | ៨,៥% | ២៦,១ |
| ទន្លេសាប | ២៤៦ | ៦៧,២% | ១២,៦ | ៤,០៤ | ៤,៩៨ | ៧,៩% | ៥០,៨ |
| សរុបរួម | ៥៩០ | ៥៧,៦% | ១០,៧ | ៣,១៥ | ៤,០៥ | ៥,៣% | ៣៣,៦ |

ទោះបីជាផលនេសាទប្រចាំថ្ងៃតាមគ្រួសារខ្ពស់បំផុត នៅក្នុងអំឡុងខែមេសា ដល់ខែឧសភាក៏ដោយ ក៏នៅក្នុងអំឡុងពេលនោះ គឺសមត្ថភាពនេសាទមានកម្រិតទាបជាងខ្លាំង ជាពិសេសសម្រាប់គ្រួសារនេសាទនៅតំបន់ខ្ពង់រាប និងបឹងទន្លេសាប។ ផលនេសាទមានស្ថេរភាពល្អ គឺចាប់ពីខែមិថុនា ដល់ខែធ្នូ នៅតំបន់ទំនាបលិចទឹក និងតំបន់ខ្ពង់រាប។ លទ្ធផលនេះ នាំឱ្យមានការប៉ាន់ប្រមាណផលនេសាទតាមគ្រួសារប្រចាំខែមានលក្ខណៈប្រហាក់ប្រហែលគ្នាក្នុងឆ្នាំ ២០២២ លើកលែងតែ តម្លៃការប៉ាន់ប្រមាណសម្រាប់ខែមេសារបស់គ្រួសារនេសាទនៅតំបន់ទំនាបលិចទឹក (ដ្យាក្រាមទី៤)។

ផលនេសាទប្រចាំថ្ងៃតាមគ្រួសារអ្នកនេសាទមានការប្រែប្រួលច្រើនជាងការប្រែប្រួលចំនួនថ្ងៃនៃការធ្វើនេសាទ ដែលសមត្ថភាពនេសាទមានកម្រិតខ្ពស់ជាងផងដែរសម្រាប់គ្រួសារអ្នកនេសាទនៅតំបន់ខ្ពង់រាប ដែលមានការប្រែប្រួលផ្ទុយគ្នាជាមួយនឹងទិន្នន័យតាមដានផលនេសាទសម្រាប់នៅតំបន់មេគង្គ នេះគឺដោយសារការមិនបានធ្វើការប្រមូលទិន្នន័យក្នុងខេត្តរតនគិរី (ជាផ្នែកខ្លះនៃទន្លេបី ដែលជាដៃទន្លេសំខាន់នៃទន្លេមេគង្គ) និងខេត្តដែលមិនជាប់នឹងទន្លេមេគង្គផ្សេងទៀត។




**ដ្យាក្រាមទី២.** ផលនេសាទតាមគ្រួសារប្រចាំថ្ងៃជាមធ្យម (គ.ក្រ/ថ្ងៃ) តាមតំបន់នេសាទនិងតាមខែនីមួយៗ




**ដ្យាក្រាមទី៣.** ថ្ងៃធ្វើនេសាទជាមធ្យមរបស់គ្រួសារអ្នកនេសាទ តាមតំបន់នេសាទ និងតាមខែនីមួយៗ




**ដ្យាក្រាមទី៤.** ផលនេសាទប្រចាំខែ(គ.ក្រ) តាមគ្រួសារអ្នកនេសាទ តាមតំបន់នេសាទ និងតាមខែនីមួយៗ

ផលនេសាទដែលបានប៉ាន់ប្រមាណនៅក្នុងតារាងទី៣ បានមកពីរបាយការណ៍ស្ថិតិប្រចាំខែ។ លទ្ធផលនេះសម្រាប់រយៈពេល ៩ខែ នៃការប្រមូលទិន្នន័យ រីឯការប៉ាន់ប្រមាណផលនេសាទសរុបសម្រាប់ឆ្នាំ២០២២ ត្រូវបានគណនាដោយផ្អែកលើចំនួនមធ្យមនៃផលនេសាទប្រចាំខែលើតាមនិន្នាការនៃតម្លៃប្រហាក់ប្រហែលគ្នាសម្រាប់រយៈពេល ១២ខែ។

**តារាងទី៣.** ការប៉ាន់ប្រមាណផលនេសាទសរុប (តោន) តាមតំបន់នេសាទ និងខែនីមួយៗ

| តំបន់នេសាទ | ឆ្នាំ២០២២ | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ផ្ទេរ | ៣២០ | ១.៦៩៩ | | | | | | | |
| ទំនាបលិចទឹក | ១៤.៣៤៦ | ១៩.៧០២ | ៤.២៧៥ | ៧.៤៥៣ | ៩.១៤៧ | ១៣.៩៨៤ | ១៧.២១១ | ១៥.៦៥៩ | ១៥.០៩៦ |
| ខ្ពង់រាប | ១.១៩៨ | ២.៤១៧ | ១.៩១៩ | ៣.៤៣៤ | ៤.៤៩០ | ១.៧២៩ | ៤.៤២០ | ២.២៣១ | ១.០៦៩ |
| ទន្លេសាប | ១៤.៨២៧ | ១២.១៨០ | ៧.៩១៩ | ៨.៣០២ | ១២.៣៦៣ | ១៣.៩៣១ | ២៥.៦០៩ | ២១.២៦៥ | ២០.២៦៨ |
| សរុប | ៣០.៦៩១ | ៣៥.៩៩៨ | ១៤.១១៣ | ១៩.១៨៩ | ២៦.០០០ | ២៩.២៤៤ | ៤៧.២៤០ | ៣៩.១៥៥ | ៣៦.៤៣៣ |

ការចូលរួមអតិបរមានៃភេទនិងក្រុមអាយុនីមួយៗ (អ្នកនេសាទ) គឺ ១០០% សម្រាប់តំបន់នេសាទនីមួយៗ ប្រសិនបើពួកគេធ្វើការនេសាទនៅថ្ងៃនេសាទ នោះចំនួនសរុបសម្រាប់តំបន់នេសាទនីមួយៗអាចលើសពី ១០០%

| តំបន់នេសាទ | សរុប ៩ខែ | ផលនេសាទមធ្យមប្រចាំខែ (តោន) | សរុប ២០២២ | %សរុប |
|---|---|---|---|---|
| ផ្ទេរ | | ១.០១០ | **១២.១១៤** | |
| ទំនាបលិចទឹក | ១១៦.៤៧៣ | ១២.៩៤១ | **១៥៥.២៩៧** | ៤២,២% |
| ខ្ពង់រាប | ២២.៩០៧ | ២.៥៤៥ | **៣០.៥៤៣** | ៨,៣% |
| ទន្លេសាប | ១៣៦.៦៦៤ | ១៥.១៨៥ | **១៨២.២១៩** | ៤៩,៥% |
| សរុប | **២៧៨.០៦៣** | | **៣៦៨.០៥៩** | |

ការប្រមូលទិន្នន័យនៅខេត្តតំបន់ឆ្នេរមានកម្រិតតិចតួច នាំឱ្យមានការពិបាកក្នុងការសន្មត់តម្លៃបន្ថែម (ចំនួនគ្រួសារនេសាទទឹកសាបមានភាពមិនច្បាស់លាស់) អាស្រ័យហេតុនេះ នៅតំបន់ឆ្នេរមិនត្រូវបានរាប់បញ្ចូលក្នុងការប៉ាន់ប្រមាណផលនេសាទសរុបឡើយ។ ផលនេសាទសរុបមានចំនួនច្រើនជាងគេ គឺនៅតំបន់ទន្លេសាប បន្ទាប់មកនៅតំបន់ទំនាបលិចទឹក ខ្ពង់រាប និងតំបន់ឆ្នេរមានបរិមាណផលនេសាទទាបជាងគេ។

ការចូលរួមក្នុងការនេសាទមានភាពសកម្មគឺបុរសពេញវ័យ (តារាងទី៤) ។ បុរសពេញវ័យបានចូលរួមក្នុងសកម្មភាពនេសាទច្រើនជាង ៩០% នៃសកម្មភាពនេសាទទាំងមូល ដោយឡែកការចូលរួមរបស់ស្ត្រីពេញវ័យមានកម្រិតទាបជាងបុរស ប៉ុន្តែមានកម្រិតខ្ពស់បំផុត គឺមាននៅក្នុងខេត្តតំបន់ឆ្នេរ (១៧,៥%) និងបន្ទាប់មកតំបន់បឹងទន្លេសាប (១២,១%)។ ក្មេងប្រុសមានការចូលរួមខ្ពស់ជាងក្មេងស្រី ប៉ុន្តែមានកម្រិតទាបជាងអ្នកនេសាទជាស្ត្រីពេញវ័យ។

**តារាងទី៤.** សមាមាត្រនៃថ្ងៃធ្វើនេសាទ ដែលមនុស្សពេញវ័យ និងកុមារចូលរួមនឹងសកម្មភាពនេសាទ[2]។

| | ស្ត្រីពេញវ័យ | បុរសពេញវ័យ | ក្មេងស្រី | ក្មេងប្រុស |
|---|---|---|---|---|
| **ឆ្នេរ** | ១៧,៨% | ៩០,០% | ០,០% | ៨,៩% |
| **ទំនាបលិចទឹក** | ៨,១% | ៨៩,៤% | ១,៦% | ៧,១% |
| **ខ្ពង់រាប** | ៥,៨% | ៩៧,០% | ០,៥% | ១,៧% |
| **ទន្លេសាប** | ១២,១% | ៨៩,១% | ១,៥% | ៤,៧% |
| **សរុបរួម** | ៩,៣% | ៩១,៥% | ១,២% | ៤,៥% |

ដូចបានបង្ហាញនៅក្នុងតារាងទី៥ ផលនេសាទប្រមាណ ៦៣,៣% នៅខេត្តតំបន់ឆ្នេរគឺនេសាទដោយប្រើទូកមិនប្រើម៉ាស៊ីន។ ផលនេសាទដោយមិនប្រើទូក គឺខ្ពស់បំផុតសម្រាប់តំបន់ទំនាបលិចទឹក និងទន្លេសាប។ ទូកប្រើម៉ាស៊ីនបានចូលរួមចំណែកខ្ពស់ជាង ៥០% នៃផលនេសាទសម្រាប់អ្នកនេសាទនៅតំបន់ខ្ពង់រាប នេះបានបង្ហាញថាមានការប្រើប្រាស់ទូកមានម៉ាស៊ីនច្រើនលើកន្លែងនេសាទដែលនៅឆ្ងាយពីផ្ទះអ្នកនេសាទ។

**តារាងទី៥.** ផលនេសាទ (គ.ក្រ) ឆ្នាំ២០២២ ជាមួយនឹងសមាមាត្រផលនេសាទ តាមប្រភេទទូក តាមតំបន់នេសាទ

| តំបន់នេសាទ | ផលនេសាទ (គ.ក្រ) | មិនមានទូក | ទូកប្រើម៉ាស៊ីន | ទូកគ្មានម៉ាស៊ីន |
|---|---|---|---|---|
| **ឆ្នេរ** | ១៨៩,៧ | ៣៦,៧% | ០,០% | ៦៣,៣% |
| **ទំនាបលិចទឹក** | ៣.៥៥៩,៨ | ៥៤,៣% | ២៨,២% | ១៧,៥% |
| **ខ្ពង់រាប** | ៣.០៦៥,៤ | ២៩,៣% | ៥៤,៦% | ១៦,១% |
| **ទន្លេសាប** | ៧.១១៧,៥ | ៦១,៥% | ២៩,៨% | ៨,៧% |
| **សរុបរួម** | ១៣.៩៣២,៤ | ៥២,៣% | ៣៤,៤% | ១៣,៣% |

សមាមាត្រសរុបដោយផ្អែកលើផលនេសាទតាមទម្ងន់ជាមធ្យម តាមប្រភេទទូកចម្បងៗនិងតំបន់នេសាទ មិនមែនជារបាយការណ៍ផលនេសាទសរុបទេ[3]។

[2] មិនមានចំនួនអ្នកនេសាទជាក់លាក់ ប៉ុន្តែការប៉ាន់ប្រមាណផ្អែកលើការសម្ភាសន៍ជ្រើសរើសគ្រួសារនេសាទ ចំនុចនេះនឹងធ្វើការវាយតម្លៃបន្ថែមទៀតក្នុងកំឡុងឆ្នាំ២០២៣។

[3] នេះជាវិធីស្តង់ដារក្នុងការគណនា ប៉ុន្តែមិនត្រូវបានអនុវត្តសម្រាប់ជម្រកនេសាទនិងផលនេសាទតាមឧបករណ៍ទេ ព្រោះវាមានភាពស្មុគស្មាញដោយសារថ្ងៃនេសាទ ដែលផលនេសាទបានរាយការណ៍មកពីជម្រកច្រើន ឬចាប់បានពីឧបករណ៍ច្រើន។




**ដ្យាក្រាមទី៥.** ការរួមចំណែកសរុបនៃប្រភេទទូក ធៀបទៅនឹងផលនេសាទសរុប

ទីជម្រកសំខាន់ៗ ដូចមានបង្ហាញក្នុងដ្យាក្រាមទី៦ រួមមានតំបន់ទំនាបលិចទឹក តាមដងទន្លេមេគង្គ ស្ទឹង ប្រឡាយធារាសាស្ត្រ និងជម្រកនេសាទផ្សេងៗទៀត។ ជម្រកសំខាន់ៗនៃតំបន់ទំនាបលិចទឹក គឺវាលស្រែរងទឹកភ្លៀង (៤៩,៩%) និង បឹង ត្រពាំង (៤៣,៣%) ដោយឡែកតំបន់ព្រៃលិចទឹក (៣,៦%) និងវាលស្រែទឹកជំនន់(ស្រែជម្រៅ) (៣,២%) មានការរួមចំណែកតិចនៅក្នុងផលនេសាទសរុប។ តំបន់ព្រៃលិចទឹក និងតំបន់វាលស្រែទឹកជំនន់(ស្រែជម្រៅ) ការចូលរួមចំណែកតិច គឺដោយសារតំបន់ព្រៃលិចទឹកភាគច្រើនស្ថិតនៅក្នុងតំបន់ការពារ ហើយគ្រួសារអ្នកនេសាទទំនងជាពិបាកបែងចែកវាលស្រែទឹកជំនន់ចេញពីវាលស្រែទឹកភ្លៀង[4]។




**ដ្យាក្រាមទី៦.** ការចូលរួមចំណែករួមនៃទីជម្រកធៀបទៅនឹងផលនេសាទសរុប និងសមាមាត្រនៃការនេសាទក្នុងទីជម្រកទំនាបលិចទឹក

[4] លុះត្រាតែអ្នកប្រមូលទិន្នន័យបានចង្អុលបង្ហាញជាក់លាក់ពីភាពខុសគ្នារវាងស្រែរងរបបទឹកភ្លៀងនិងស្រែស្រោចស្រព នោះអ្នកឆ្លើយតបសំនួរនឹងចាត់ទុកជាជម្រកដូចគ្នា។

**តារាងទី៦**. សមាមាត្រ និងផលនេសាទតាមទីជម្រក សម្រាប់ជម្រកតែមួយ តាមតំបន់នេសាទ

| ជម្រកនេសាទ | ឆ្នេរ | ទំនាបលិចទឹក | ខ្ពង់រាប | ទន្លេសាប | សរុប |
|---|---|---|---|---|---|
| ដងទន្លេមេគង្គ | ០,០% | ១៨,៩% | ៥៤,៣% | ០,០% | ១៩,៣% |
| ទំនាបលិចទឹក: វាលស្រែ ( ទឹកភ្លៀង ) | ១៧,៦% | ២២,៦% | ១,១% | ២១,៧% | ១៦,៥% |
| ទំនាបលិចទឹក: បឹង និងត្រពាំង | ៧,៥% | ៣០,៩% | ១២,៥% | ៥,៧% | ១៤,៤% |
| អូរ | ០,៦% | ៥,៧% | ១៧,១% | ៩,៦% | ១០,៤% |
| ប្រឡាយជារាសាស្រ្ត | ១៤,៥% | ៨,៧% | ៤,៥% | ១០,០% | ៨,៣% |
| មិនមានបញ្ជាក់ពីទីជម្រក | ០,០% | ១,៥% | ០,១% | ១៦,០% | ៧,៧% |
| ស្ទឹងនានាហូរចូលបឹងទន្លេសាប | ០,០% | ២,២% | ០,០% | ១៥,៦% | ៧,៧% |
| ស្ទឹង | ៥៨,៩% | ០,៨% | ០,០% | ១៣,៧% | ៧,២% |
| អាងស្តុកទឹក | ០,០% | ១,១% | ៤,០% | ៥,១% | ៣,៧% |
| ដៃទន្លេចម្បងៗ | ០,០% | ៥,៣% | ០,០% | ០,០% | ១,៥% |
| វាលភក់តាមរដូវ | ០,០% | ០,៩% | ២,៣% | ០,៨% | ១,២% |
| ទំនាបលិចទឹក: ព្រៃលិចទឹក | ០,០% | ០,៩% | ៣,៦% | ០,០% | ១,២% |
| ទំនាបលិចទឹក: វាលស្រែ ( ទឹកជំនន់ ) | ០,៩% | ០,៤% | ០,៦% | ១,៧% | ១,១% |
| | ១៧២,៨ | ៣.៨៨០,៣ | ៣.៧២១,៦ | ៦.៥០៧,០ | ១៤.២៨១,៧ |

មានរួមបញ្ចូលតែផលនេសាទ នៅថ្ងៃណា ដែលគេរាយការណ៍ពីការនេសាទពីជម្រកតែមួយប៉ុណ្ណោះ។

ភាពខុសគ្នារវាងតំបន់នេសាទ (តារាងទី៦) បានបង្ហាញពីលក្ខណៈធម្មជាតិនៃធនធានជលផល ដោយការនេសាទតាមដងទន្លេមេគង្គមានសារៈសំខាន់បំផុតសម្រាប់គ្រួសារនៅតំបន់ខ្ពង់រាប និងបន្ទាប់មកការនេសាទសម្រាប់តំបន់ទំនាបលិចទឹក។ ដៃទន្លេចំបងៗ គឺមានសារៈសំខាន់សម្រាប់តែអ្នកនេសាទនៅតំបន់ទំនាបលិចទឹក ដែលភាគច្រើនសំដៅទៅលើទន្លេសាប។ ការមិនបានបញ្ចូលការនេសាទនៅតាមដៃទន្លេចំបងៗសម្រាប់គ្រួសារអ្នកនេសាទនៅតាមតំបន់ខ្ពង់រាប គឺបង្ហាញពីការគ្របដណ្តប់នៃការប្រមូលទិន្នន័យមិនបានពេញលេញសម្រាប់ប្រជានេសាទដែលនៅតាមដងទន្លេ បើប្រៀបធៀបទៅនឹងការធ្វើនេសាទនៅតាមដងទន្លេមេគង្គ។ ពុំមានផលនេសាទបានពី "ស្ទឹង" ឡើយ ប៉ុន្តែមានផលនេសាទជាង ១៧% នេសាទបានពី "អូរ" ។

ការនេសាទនៅតាមទីជម្រកនេសាទផ្សេងៗទៀត (ក្រៅពីទីជម្រកដែលបានបញ្ជាក់ខាងលើ) គឺភាគច្រើនមាននៅតំបន់ទន្លេសាប ហើយទីជម្រកទាំងនេះនឹងត្រូវធ្វើការកែលម្អក្នុងអំឡុងការអនុវត្តការប្រមូលទិន្នន័យឆ្នាំ២០២៣។

ឧបករណ៍នេសាទសំខាន់បំផុត ដោយផ្អែកលើការរួមចំណែកទៅនឹងផលនេសាទ (ដ្យាក្រាមទី៧ក) រួមមាន៖មងកាំង (៣៤,៤%) លប (១៩,៨%) និងសំណាញ់ (១៦,១%) ដែលបានរួមចំណែកផលនេសាទខ្ពស់ ហើយក្នុងនោះដែរ មងកាំងមានការប្រើប្រាស់ច្រើនជាងមងបណ្តែត។




ដ្យាក្រាមទី៧ក. ការចូលរួមចំណែកសរុបនៃប្រភេទឧបករណ៍នេសាទទៅនឹងផលនេសាទសរុប

ស្រដៀងគ្នាទៅនឹងជម្រកនេសាទដែរ ការរួមចំណែកនៃឧបករណ៍នេសាទធៀបទៅនឹងផលនេសាទ គឺភាគច្រើនអាស្រ័យទៅលើស្ថានភាពផ្សេងគ្នានៃតំបន់នេសាទ ប៉ុន្តែភាពខុសគ្នានៃការប្រើប្រាស់ឧបករណ៍នេសាទ គឺតិចជាងភាពខុសគ្នានៃទីជម្រក។ ទោះបីជាមានភាពខុសប្លែកគ្នាមួយចំនួន (តារាងទី៧) ក៏លទ្ធផលបានបង្ហាញថា មងកាំងជាឧបករណ៍នេសាទដែលបានចូលរួមចំណែកច្រើននៅក្នុងផលនេសាទនៅតំបន់ខ្ពង់រាប ហើយសំណាញ់នៅតំបន់បឹងទន្លេសាប ចំណែកឯ លបជាឧបករណ៍នេសាទដែលបានចូលរួមចំណែកស្ទើរតែស្មើៗគ្នានៅគ្រប់តំបន់នេសាទទាំងអស់ ប៉ុន្តែលបតូច មានការចូលរួមចំណែកច្រើនជាងលបធំ។

ឧបករណ៍ដទៃទៀត (ក្រៅពីឧបករណ៍នេសាទដែលបានរៀបរាប់ខាងលើ) ឃើញមានប្រើប្រាស់នៅក្នុងគ្រប់តំបន់នេសាទទាំងអស់ ប៉ុន្តែមានច្រើនជាងគេនៅតំបន់ខ្ពង់រាប។

**តារាងទី៧**. សមាមាត្រ និងផលនេសាទតាមឧបករណ៍នេសាទ និងតាមតំបន់នេសាទ

| ឧបករណ៍នេសាទ | ឆ្នេរ | ទំនាបលិចទឹក | ខ្ពង់រាប | ទន្លេសាប | សរុប |
|---|---|---|---|---|---|
| មងកាំង | ៤៥,០% | ២៤,៦% | ៥០,២% | ៣៤,៤% | ៣៥,៦% |
| លប (តូច) | ២,៨% | ១៣,៤% | ១១,០% | ១៩,៨% | ១៥,៩% |
| សំណាញ់ | ១៣,៥% | ៨,៣% | ៣,០% | ១៦,១% | ១១,២% |
| មងបណ្ដែត | ០,០% | ១៨,៨% | ៦,៣% | ៦,៥% | ៩,៥% |
| ចាប់ដោយដៃ | ១៤,១% | ១០,២% | ១,២% | ១០,៦% | ៨,៤% |
| មិនមានបញ្ជាក់ពីប្រភេទឧបករណ៍ | ៤,៩% | ៧,៦% | ១៨,៥% | ៣,៤% | ៧,៩% |
| សន្ទូចរាយ | ០,០% | ២,៨% | ៦,៣% | ១,១% | ២,៧% |
| សន្ទូចបង្កៃ/វាត់/បង្កង | ០,០% | ១,០% | ១,៥% | ៣,១% | ២,១% |
| លប (ធំ) | ១,១% | ២,២% | ០,៧% | ១,៩% | ១,៧% |
| សៃយឺន | ៧,៥% | ៣,៤% | ០,៤% | ០,៨% | ១,៥% |

| | | | | | |
|---|---|---|---|---|---|
| ស្ទូ/សម/ច្បូក | ១១,១% | ៣,៣% | 0,១% | 0,៤% | ១,២% |
| បូម | 0,0% | ៣,២% | 0,0% | 0,0% | 0,៨% |
| ឈឹប | 0,0% | 0,0% | 0,0% | ១,១% | 0,៦% |
| សន្ទូច | 0,0% | 0,២% | 0,៣% | 0,៥% | 0,៤% |
| ឈ្នាង | 0,0% | 0,៨% | 0,0% | 0,១% | 0,២% |
| ចាន់ | 0,0% | 0,0% | 0,៣៥% | 0,0% | 0,១% |
| ថ្នង | 0,0% | 0,0% | 0,១២% | 0,0៥% | 0,១% |
| ដាយ | 0,0% | 0,0% | 0,0% | 0,0៨% | 0,0៤% |
| អង្រុត/សង្គ្រប់ | 0,0% | 0,១២% | 0,0% | 0,0% | 0,0៣% |
| ប៉ោង | 0,0% | 0,0% | 0,0៩% | 0,0% | 0,0២% |
| តុម | 0,0% | 0,0៧% | 0,0% | 0,0% | 0,0២% |
| អួន | 0,0% | 0,0៦% | 0,0% | 0,0% | 0,0១% |
| ស្នា និងកាំភ្លើង | 0,0% | 0,0% | 0,0% | 0,0២% | 0,0១% |
| ជុចត្រីរ៉ស់ | 0,0% | 0,0% | 0,0% | 0,0% | <0,0១% |

តាមរាងខាងលើមានបញ្ចូលតែផលនេសាទណា ដែលមានមកដោយប្រើឧបករណ៍តែមួយ ដូច្នេះផលនេសាទសរុបគឺខុសពីផលនេសាទតាមជម្រក ដែលបានរាយការណ៍។

បើយកចំនួនថ្ងៃដែលបានធ្វើនេសាទ ធៀបនឹងផលនេសាទ គឺសង្កេតឃើញថា មិនមានភាពខុសប្លែកគ្នាជាមួយនឹងទំនាក់ទំនងនៃការប្រើប្រាស់ឧបករណ៍នេសាទឡើយ។ ប៉ុន្តែ មានភាពខុសប្លែកគ្នាតាមរដូវចំពោះឧបករណ៍មួយចំនួន (ដ្យាក្រាមទី៧ខ)។ ការចាប់ដោយដៃ គឺមានច្រើនបំផុតនៅរដូវប្រាំង ដោយឡែកលបតូចៗប្រើច្រើនបំផុត ចាប់ពីខែកក្កដា ដល់ខែធ្នូ និងមានប្រើតិចតួចចាប់ពីខែមេសា ដល់ខែមិថុនា។ ចំពោះការនេសាទដោយសំណាញ់វិញ គឺជាទូទៅនេសាទពេញមួយឆ្នាំ ប៉ុន្តែច្រើនបំផុត ក្នុងអំឡុងដើមរដូវប្រាំង និងពេលត្រីសម្បូរជាងគេក្នុងអំឡុងពេលនៃរដូវប្រាំងនោះ។




**ដ្យាក្រាមទី៧ខ.** ការរួមចំណែកផលនេសាទប្រចាំខែសរុបតាមប្រភេទឧបករណ៍នេសាទដែលចាប់បានច្រើនជាងគេចំនួន៥ និងតាមខែនីមួយៗ

ដូចមានបង្ហាញជូនក្នុងតារាងទី៨ តំបន់ទំនាបលិចទឹក និងបឹងទន្លេសាបលក់ត្រី/ផលនេសាទខ្ពស់បំផុត ប្រមាណ ៥៥% នៅតំបន់ទំនាបលិចទឹក និង៤៨% នៅតំបន់ទន្លេសាប ហើយផលនេសាទ ២៨% នៅតំបន់ទំនាបលិចទឹក និង ៣២% នៅតំបន់ទន្លេសាបត្រូវបានប្រើប្រាស់ក្នុងគ្រួសារ។ ការប្រើប្រាស់ផលនេសាទក្នុងគ្រួសារភាគច្រើន ជាត្រី និងពពួកវារីសត្វផ្សេងទៀត (OAA) ហើយផលនេសាទទាំងនេះត្រូវបានប្រើប្រាស់ស្រស់។ ផលនេសាទក៏ត្រូវបានគេប្រើប្រាស់ជាបម្លងសម្រាប់កែច្នៃ រួមទាំងការប្រើប្រាស់សម្រាប់វារីវប្បកម្ម រួមទាំងការចិញ្ចឹមក្រពើ តាមគ្រួសារផងដែរ។ តាមរយៈលទ្ធផលនេះ គឺបានបង្ហាញពីភាពខុសគ្នាតិចតួចរវាងតំបន់នេសាទទាំង៣។

**តារាងទី៨.** ការប្រើប្រាស់ផលនេសាទតាមតំបន់នេសាទតាមទម្ងន់ និងសមាមាត្រ

| តំបន់នេសាទ | លក់ (គ.ក្រ) | %លក់ | ប្រើប្រាស់ (គ.ក្រ) | %បរិភោគ | ផ្សេងទៀត (គ.ក្រ) | %ផ្សេងទៀត |
|---|---|---|---|---|---|---|
| ឆ្នេរ | ១០២,០ | ៤៣,៥% | ១១១,៨ | ៤៧,៦% | ២០,៩ | ៨,៩% |
| ទំនាបលិចទឹក | ២.៤៥៣,០ | ៥៤,៨% | ១.២៥៨,១ | ២៨,១% | ៧៦៦,៦ | ១៧,១% |
| ខ្ពង់រាប | ១.៤០១,៤ | ៣៥,៧% | ១.៨២២,៨ | ៤៦,៤% | ៧០៥,១ | ១៧,៩% |
| ទន្លេសាប | ៤.៣១៤,១ | ៤៧,៩% | ២.៨៨៥,៥ | ៣២,០% | ១.៨០៤,៥ | ២០,០% |
| សរុប | ៨.២៧០,៥ | ៤៦,៩% | ៦.០៧៨,២ | ៣៤,៤% | ៣.២៩៧,២ | ១៨,៧% |

ចំពោះផលនេសាទភាគច្រើន បើគិតជារួមនៅក្នុងតំបន់នេសាទទាំងអស់ គឺភាគច្រើនសម្រាប់លក់[5] (ដ្យាក្រាមទី៨)។ ក្នុងនោះផងដែរ ការប្រើប្រាស់ក្នុងគ្រួសារមានប្រមាណ ៣៤,៤%និងប្រើប្រាស់ផ្សេងៗទៀតប្រមាណ ១៨,៧%។




**ដ្យាក្រាមទី៨.** ការប្រើប្រាស់ផលនេសាទរួមសម្រាប់ឆ្នាំ២០២២

[5] ផ្អែកលើទម្ងន់ស្តង់ដារសម្រាប់ផ្នែកប្រើប្រាស់ តាមតំបន់នេសាទ




**ដ្យាក្រាមទី៩.** សមាមាត្រផលនេសាទសរុបដែលបានលក់ប្រចាំខែ និងតាមតំបន់នេសាទនីមួយៗ

ការលក់ផលនេសាទ ជាទូទៅមានច្រើនជាងគេនៅរដូវប្រាំង នៅក្នុងតំបន់ទំនាបលិចទឹក និងទន្លេសាប។ នៅតំបន់ទំនាបលិចទឹកមានការលក់ផលនេសាទច្រើន នៅក្នុងអំឡុងខែដែលមានផលនេសាទខ្ពស់បំផុតចាប់ពីខែកញ្ញា ដល់ខែវិច្ឆិកា។ សមាមាត្រផលនេសាទដែលបានលក់តិចតួចបំផុត គឺនៅតំបន់ខ្ពង់រាប ហើយការលក់ផលនេសាទកាន់តែតិចតួចខ្លាំងនៅអំឡុងដើមរដូវប្រាំង (ដ្យាក្រាមទី៩)។




ដ្យាក្រាមទី១០. ការរួមចំណែករួមនៃផលនេសាទ (ត្រី និងវារីសត្វផ្សេងទៀត) ក្នុងឆ្នាំ២០២២

ជាលទ្ធផលបង្ហាញថា ត្រីតំណាងឱ្យភាគច្រើនលើសលប់នៃផលនេសាទរួម (ដ្យាក្រាមទី១០)។ ទោះបីជាមានការប្រែប្រួលតាមរដូវកាលខ្លះក៏ដោយ (ដ្យាក្រាមទី១១) ក៏ជាលទ្ធផលប្រហាក់ប្រហែលជាមួយនឹងការសិក្សាអំពីការប្រើប្រាស់របស់ IFReDI នាពេលកន្លងមក។ ការសិក្សាកន្លងមកនេះ បានរកឃើញថា ជាមធ្យមការរួមចំណែកនៃ OAA គឺមានចំនួនតិចជាង ១០% នៃផលនេសាទទឹកសាបសរុប។




**ដ្យាក្រាមទី១១.** ផលនេសាទត្រី និងវារីសត្វផ្សេងទៀត (គ.ក្រ) តាមខែនីមួយៗ

ខាងក្រោម (តារាងទី៩) គឺជាផលនេសាទខ្ពស់ជាងគេទាំង ២០ប្រភេទ៖

- ក្រុមប្រភេទ (រួមមាន ក្រុម sp. និងក្រុម nei[6]) តំណាងឱ្យ ១៣,៤% នៃផលនេសាទសរុប
- មានប្រភេទមិនមែនត្រីតែមួយគត់ស្ថិតក្នុងប្រភេទទាំង២០ ដែលនេសាទបានខ្ពស់ជាងគេ គឺពពួកក្តាម (*Somanniathelpusa sp.*) កង្កែប (*Rana tigrina*) និងកំពឹសចម្រុះតូចៗ និង
- ផលនេសាទខ្ពស់ជាងគេទាំងក្នុងចំនួន២០ប្រភេទនេះ គឺតំណាងឱ្យ ៦៩% នៃផលនេសាទសរុប[7] (ប្រភេទសរុបចំនួន ១០១ប្រភេទ និងក្រុមប្រភេទ)។

---

[6] nei: គ្មានក្នុងក្រុមដ៏ទៃ

[7] ប្រភេទ ដែលជាអំបូរនៃ Henicorhynchus នៅពេល ដែលដាក់ក្រុមប្រភេទនេះរួមបញ្ចូលគ្នា ទម្ងន់សរុបនឹងស្ថិតក្នុងលេខរៀងទី៤ ឬប្រហែល ៧% នៃផលនេសាទសរុប។

**តារាងទី៩.** ប្រភេទ និងទម្ងន់វារីសត្វដែលនេសាទបានច្រើនជាងគេទាំង២០ នឹងសមាមាត្រនៃផលនេសាទ តាមប្រភេទនីមួយៗ និងក្រុមប្រភេទ

| | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះភាសាខ្មែរ | ផលនេសាទ (គ.ក្រ) | ការរួមចំណែកនៃផលនេសាទ | |
|---|---|---|---|---|---|
| | | | | សមាមាត្រ | ការបូកយោង |
| 1 | *Channa striata* | ត្រីរ៉ស់/ផ្ទក់ | ១.៤៣៣,៦ | ៨,៤% | ៨,៤% |
| 2 | *Anabas testudineus* | ត្រីក្រាញ់ | ១.៣៤៤,០ | ៧,៩% | ១៦,៣% |
| 3 | *Henicorhynchus lobatus* | ត្រីរៀលអង្កាម | ១.០៨៨,៧ | ៦,៤% | ២២,៧% |
| 4 | *Puntioplites proctozysron* | ត្រីច្រកែង | ១.០៤៩,២ | ៦,២% | ២៨,៨% |
| 5 | *Henicorhynchus siamensis* | ត្រីរៀលតុប | ៩៥៤,២ | ៥,៦% | ៣៤,៤% |
| 6 | *Somanniathelphusa sp.* | ក្តាមស្រែ | ៩២៤,៤ | ៥,៤% | ៣៩,៨% |
| 7 | *Trichopodus trichopterus* | ត្រីកំភ្លាញស្រែ | ៧១៩,៣ | ៤,២% | ៤៤,០% |
| 8 | *Barbonymus gonionotus* | ត្រីឆ្ពិនប្រាក់ | ៥៩៥,២ | ៣,៥% | ៤៧,៥% |
| 9 | Mixed small or juvenile fish | ត្រីល្អិតចម្រុះ | ៥៧១,០ | ៣,៣% | ៥០,៩% |
| 10 | *Clarias batrachus* | ត្រីអណ្តែងរឹង | ៤៦០,១ | ២,៧% | ៥៣,៦% |
| 11 | Unspecified | មិនមានបញ្ជាក់ | ៤០៩,៨ | ២,៤% | ៥៦,០% |
| 12 | *Hemibagrus spilopterus* | ត្រីឆ្លាំង | ៣៦២,៦ | ២,១% | ៥៨,១% |
| 13 | *Labiobarbus siamensis* | ត្រីអាចម៍កុក | ៣០១,៦ | ១,៨% | ៥៩,៩% |
| 14 | *Rana tigrina* | លៀស | ២៧០,០ | ១,៦% | ៦១,៥% |
| 15 | *Small mixed shrimps* | កំពឹសចម្រុះ | ២៣២,៦ | ១,៤% | ៦២,៨% |
| 16 | *Macrognathus siamensis* | ត្រីឆ្លូញ | ២២១,២ | ១,៣% | ៦៤,១% |
| 17 | *Osteochilus lini* | ត្រីក្រុស | ២១៨,០ | ១,៣% | ៦៥,៤% |
| 18 | *Fejervarya limnocharis* | កង្កែប | ២០៩,៨ | ១,២% | ៦៦,៦% |
| 19 | *Hypsibarbus malcolmi* | ត្រីឆ្ពិនមូល | ២០២,៣ | ១,២% | ៦៧,៨% |
| 20 | *Cyclocheilichthys enoplos* | ត្រីឆ្កោក | ១៩៤,៨ | ១,១% | ៦៩,០% |
| | Others | ផ្សេងទៀត | ៥.២៩៥,៦ | ៣៧,២% | ៩៨,៦% |
| | **ផលនេសាទរាយការណ៍សរុប** | | **១៧.០៨៥,០** | | |

ភាពចម្រុះនៃប្រភេទ និងការរួមចំណែកតិចតួចតាមក្រុមនៃប្រភេទវារីសត្វនៅក្នុងផលនេសាទ គឺបានផ្តល់នូវមូលដ្ឋានទិន្នន័យយ៉ាងសំខាន់ក្នុងការរៀបចំរបាយការណ៍ផលនេសាទតាមប្រភេទ ដែលប្រភេទទាំងនេះ គឺផ្អែកទាំងស្រុងតាមឈ្មោះជាភាសារខ្មែរដែលហៅតាមតំបន់នេសាទ។ យ៉ាងណាមិញ ផលនេសាទដែលមិនមានបញ្ជាក់ពីប្រភេទវារីសត្វច្បាស់លាស់ ដោយមិនមានកត់ត្រាឈ្មោះប្រភេទមានប្រមាណ ២,៤% នៃផលនេសាទ ហើយចំណុចនេះនឹងត្រូវធ្វើការកែលម្អនៅពេលខាងមុខ។

ភាពចម្រុះនៃប្រភេទវារីសត្វខ្ពស់បំផុតមាននៅខែសីហា ឧសភា និងតុលា (តារាងទី១០)។ លទ្ធផលនេះ គឺមានការប្រែប្រួលនៅខែឧសភា ដោយសារនៅខែនេះមានសំណាកគ្រួសារខ្ពស់ជាងគេ ហើយជាខែចុងក្រោយដែលបានរួមបញ្ចូលទិន្នន័យខេត្តនៅតំបន់ឆ្នេរ។ សមាមាត្រនៃក្រុមប្រភេទវារីសត្វមានការប្រែប្រួលច្រើនក្នុងអំឡុងពេញមួយឆ្នាំ

ប៉ុន្តែជាទូទៅ បម្រែបម្រួលនេះមានកម្រិតទាបបំផុតនៅរដូវប្រាំង និងខ្ពស់បំផុតនៅរដូវវស្សា។ តាមការវិភាគដោយប្រើសន្ទស្សន៍នៃជីវចម្រុះ (Biodiversity Indices) គឺបង្ហាញថា នៅខែសីហាមានសន្ទស្សន៍នៃជីវចម្រុះខ្ពស់បំផុត តម្លៃនេះគឺមានភាពស៊ីសង្វាក់គ្នាទៅនឹងភាពសម្បូរនៃប្រភេទ (Evenness) ដែលមានតម្លៃខ្ពស់បំផុតដែរ (ប្រភេទមានសម្បូរដូចគ្នា)។ មិនមានការប្រៀបធៀបស៊ីជម្រៅរវាងតំបន់នេសាទ ឬការរួមចំណែកតាមក្រុមប្រភេទត្រី និងភាពសម្បូរនៃប្រភេទត្រីចម្បងៗនៅក្នុងដែនទឹកនិងទីជម្រកជាក់លាក់ (main fish assemblage groups[8] ) ឡើយ។

**តារាងទី១០.** ចំនួនប្រភេទ សន្ទស្សន៍នៃជីវចម្រុះ និងសមាមាត្រនៃក្រុមប្រភេទតាមខែនៅក្នុងតំបន់នេសាទទាំងអស់

| ឆ្នាំ២០២២ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| # ប្រភេទ | ៥២ | ៦៥ | ៥២ | ៦២ | ៦៦ | ៦០ | ៦៤ | ៥៨ | ៥៤ |
| Shannon | ៣,០៣២៨ | ៣,៣៣៨៤ | ៣,២២៧៨ | ៣,១៩៩០ | ៣,៤៦១៧ | ៣,២១០៥ | ៣,២៤១០ | ៣,០៧៣៧ | ២,៨៦៧២ |
| ភាពចម្រុះនៃប្រភេទ (Evenness) | ០,៧៦៧៦ | ០,៧៩៩៧ | ០,៨១៦៩ | ០,៧៧៥១ | ០,៨២៦៣ | ០,៧៨៤១ | ០,៧៧៩៣ | ០,៧៥៧០ | ០,៧១៨៨ |
| %ក្រុម | ៤,១% | ១១,៦% | ៩,០% | ១៤,២% | ១២,៨% | ១៩,៩% | ១៩,៧% | ១៥,០% | ៩,៩% |
| %ប្រភេទ | ៩៥,៩% | ៨៨,៤% | ៩១,០% | ៨៥,៨% | ៨៧,២% | ៨០,១% | ៨០,៣% | ៨៥,០% | ៩០,១% |
| ផលនេសាទ (គ.ក្រ) | ១៥៥៦ | ៣២៨១ | ៨៩៨ | ១៣៤៨ | ១៨២១ | ១៦១១ | ២៦៦៥ | ២០២០ | ១៧១៤ |

ផលនេសាទសរុបមិនរាប់បញ្ចូលផលនេសាទពីតំបន់ឆ្នេរ ដូច្នេះវាខុសពីតារាងផ្សេងទៀត ការដាក់ពណ៌ហាយឡាយលើទិន្នន័យក្នុងតារាងខាងលើនេះបង្ហាញពីតម្លៃសន្ទស្សន៍នៃភាពចម្រុះធៀបនឹង ក្នុងអំឡុងឆ្នាំ២០២២។

ទោះបីជាមានការប្រែប្រួលខ្លះលើតម្លៃនៃផលនេសាទតាមប្រភេទមួយចំនួនក៏ដោយ ក៏ប្រភេទទាំង ១០ ដែលនេសាទបានខ្ពស់ជាងគេ (តារាងទី១១) មានទម្ងន់ស្មើរតែដូចគ្នា (តារាងទី៩)។ ប្រភេទនេសាទបានខ្ពស់ជាងគេទាំង ២០ ប្រភេទ មានប្រមាណច្រើនជាង ៧២% នៃតម្លៃសរុប លទ្ធផលនេះបង្ហាញថា ប្រភេទទាំងនេះជាប្រភេទដែលមានសារៈសំខាន់ខាងសេដ្ឋកិច្ច។

---

[8] សំដៅលើត្រីស ត្រីខ្មៅ និងត្រីប្រផេះ ដែលកំណត់ឈ្មោះតាមឥរិយាបថធ្វើចំណាកស្រុកនិងជម្រក ដែលគេបានសម្គាល់។

**តារាងទី១១.** វារីសត្វចាប់បានច្រើនជាងគេទាំង ២០ប្រភេទ (១០០០រៀល) សមាមាត្រតម្លៃ និងតម្លៃមធ្យមសម្រាប់ឆ្នាំ២០២២

| | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះភាសាខ្មែរ | តម្លៃ (១០០០រៀល) | ការរួមចំណែកនឹងតម្លៃ | | តម្លៃ (រៀល) |
|---|---|---|---|---|---|---|
| | | | | %តម្លៃ | %បូកយោង | |
| 1 | *Channa striata* | ត្រីរ៉ស់/ផ្ទក់ | ១៧.៨៩៩ | ១៦,២% | ១៦,២% | ៥.០០០ |
| 2 | *Henicorhynchus lobatus* | ត្រីរៀលអង្កាម | ៦.៨០២ | ៦,១% | ២២,៣% | ៣.៥០០ |
| 3 | *Anabas testudineus* | ត្រីក្រាញ់ | ៦.៧៦៧ | ៦,១% | ២៨,៤% | ៣.០០០ |
| 4 | *Henicorhynchus siamensis* | ត្រីរៀលគុប | ៦.៦១២ | ៦,០% | ៣៤,៤% | ៤.០០០ |
| 5 | *Puntioplites proctozysron* | ត្រីច្រកែង | ៤.៩៣៨ | ៤,៥% | ៣៨,៨% | ៣.៥០០ |
| 6 | *Barbonymus gonionotus* | ត្រីឆ្ពិនប្រាក់ | ៤.៦៤២ | ៤,២% | ៤៣,០% | ៥.០០០ |
| 7 | *Hemibagrus spilopterus* | ត្រីឆ្លាំង | ៤.១២២ | ៣,៧% | ៤៦,៧% | ៦.៥០០ |
| 8 | *Clarias batrachus* | ត្រីអណ្តែងរឹង | ៣.៨៤០ | ៣,៥% | ៥០,២% | ៤.០០០ |
| 9 | *Trichopodus trichopterus* | ត្រីកំភ្លាញស្រែ | ៣.៥៤២ | ៣,២% | ៥៣,៤% | ២.៥០០ |
| 10 | *Macrognathus siamensis* | ត្រីឆ្លូញ | ៣.៤៧៤ | ៣,១% | ៥៦,៥% | ៨.៥០០ |
| 11 | *Hemibagrus wyckioides* | ត្រីខ្យា | ៣.១២៧ | ២,៨% | ៥៩,៤% | ១២.០០០ |
| 12 | Mixed small or juvenile fish | ត្រីល្អិតចម្រុះ | ២.០០៨ | ១,៨% | ៦១,២% | ២.៥០០ |
| 13 | *Labiobarbus siamensis* | ត្រីអាចម៍កុក | ១.៨៦៧ | ១,៧% | ៦២,៨% | ៣.០០០ |
| 14 | *Somanniathelphusa sp.* | ក្តាមស្រែ | ១.៨៥៣ | ១,៧% | ៦៤,៥% | ១.០០០ |
| 15 | *Mystus singaringan* | ត្រីកញ្ចុះបាយស | ១.៨១៧ | ១,៦% | ៦៦,២% | ៣.៥០០ |
| 16 | *Puntius orphoides* | ត្រីអំពិលទុំ | ១.៥២៥ | ១,៤% | ៦៧,៥% | ៣.៥០០ |
| 17 | *Cyclocheilichthys enoplos* | ត្រីឆ្កោក | ១.៤៦៨ | ១,៣% | ៦៨,៩% | ៤.៥០០ |
| 18 | *Osteochilus lini* | ត្រីក្រុស | ១.៣១០ | ១,២% | ៧០,០% | ២.៥០០ |
| 19 | *Clarias cf. batrachus* | ត្រីអណ្តែងរឹង | ១.២៩៩ | ១,២% | ៧១,២% | ៤.០០០ |
| 20 | *Hypsibarbus suvattii* | ត្រីឆ្ពិនស្តើង | ១.១១១ | ១,០% | ៧២,២% | ២.០០០ |
| 21 | Other species | ប្រភេទផ្សេងទៀត | ៣០.៧៨៥ | ១១,០% | ១០០,០% | |
| | **តម្លៃផលនេសាទសរុប** | | ១១០.៨០៨ | | | |

# ៣. ការពិភាក្សានិងអនុសាសន៍

ដោយសារមានភាពយឺតយ៉ាវក្នុងការទទួលបានថវិកាសម្រាប់អនុវត្តការងារ ការចាប់ផ្តើមប្រមូលទិន្នន័យផលនេសាទត្រូវបានពន្យារពេលរហូតដល់ខែមេសា ឆ្នាំ២០២២ នេះមានន័យថា ការប្រមូលទិន្នន័យនៅអំឡុងត្រីមាសទីមួយត្រូវបានអាក់ខាន។ ទោះបីជាការប្រមូលទិន្នន័យសម្រាប់ឆ្នាំ២០២២ បានអនុវត្តល្អប្រសើរជាងឆ្នាំ២០២១ ក៏ដោយ ក៏ការតាមដានអំពីបម្រែបម្រួលផលនេសាទតាមរដូវកាលនៅតែមិនអាចបង្ហាញនូវលទ្ធផលបានពេញលេញ ដូចនេះ វាជាការចាំបាច់ណាស់ដែលការប្រមូលទិន្នន័យរយៈពេញ១២ខែ ជារៀងរាល់ឆ្នាំ ហើយត្រូវបង្កើនទំហំសំណាកដើម្បីគ្របដណ្តប់តាមខេត្តកាន់តែល្អប្រសើរ។ រដ្ឋបាលជលផល គួរជជែកជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បី

ទទួលបានឋវិកាសម្រាប់ការអនុវត្តការតាមដានផលនេសាទទឹកសាបឱ្យបានទាន់ពេលវេលា និងដើម្បីអាចអោយការប្រមូលទិន្នន័យប្រព្រឹត្តិទៅបានពេញ ១២ខែ ក្នុងមួយឆ្នាំ។

**តារាងទី១២.** ការប្រៀបធៀបផលនេសាទសរុប ដែលបានចេញផ្សាយជាផ្លូវការក្នុងឆ្នាំ២០២២ និងការប៉ាន់ប្រមាណផ្អែកលើ CAS (តោន)

| **ផលផលទឹកសាប** | **ន. ផែនការ (DPFIC)** | **IFReDI CAS** |
|---|---|---|
| ដាយត្រី | ១៣.០០០ | |
| នេសាទគ្រួសារ (ដែននេសាទ) | ២៤៧.៩០០ | ២៦០.៦៤០ |
| នេសាទគ្រួសារ (វាលស្រែ) | ១៤៥.៥០០ | ៩៩.៣៦០ |
| **សរុប** | **៤០៦.៤០០** | **៣៦៨.០០០** |

កន្លែងនេសាទតាមវាលស្រែ រួមមានៈ វាលស្រែ ជម្រកព្រៃលិចទឹក និងប្រឡាយធារាសាស្ត្រ

ការប៉ាន់ប្រមាណផ្លូវការ ដែលចេញផ្សាយដោយរដ្ឋបាលជលផល គឺផលនេសាទទឹកសាបមានចំនួន៤០៦.៤០០ តោន (តារាងទី១២) ជាមួយនឹងលទ្ធផលនៃការវាយតម្លៃផលនេសាទទឹកសាបការនេសាទលក្ខណៈគ្រួសារ (CAS) មានចំនួន ៣៩៣.៤០០តោន ។ ការប៉ាន់ប្រមាណដោយ IFReDI តាមរយៈការអនុវត្ត CAS ដែលមានចំនួន (យ៉ាងហោចណាស់) ៣៦៨.០០០តោន គឺមានលក្ខណៈប្រហាក់ប្រហែលគ្នា។ ប្រសិនជាបូករួមនឹងផលនេសាទនៃខេត្តតំបន់ឆ្នេរពេញមួយឆ្នាំនោះ ផលនេសាទសរុបសម្រាប់ឆ្នាំ២០២២ នឹងមានចំនួន ៣៨០.០០០តោន ហើយបើបន្ថែមខេត្តតំបន់ភ្នំ នោះការប៉ាន់ប្រមាណផលនេសាទទឹកសាបសរុបដោយ CAS អាចមានកម្រិតដូចគ្នាទៅនឹងការប៉ាន់ប្រមាណផ្លូវការដោយរដ្ឋបាលជលផល។ ផ្អែកលើផលនេសាទតាមទីជម្រក គឺមានផលនេសាទ ២៧% ជាផលនេសាទបានមកពីជម្រកទំនាបលិចទឹក ដែលជាប់ទាក់ទងនឹងវាលស្រែ រួមទាំងប្រឡាយធារាសាស្ត្រ រីឯរបាយការណ៍ស្ថិតិផ្លូវការរបស់រដ្ឋបាលជលផល គឺមានចំនួន ៣៧%។ ភាពខុសគ្នានេះអាចមកពីការមិនរាប់បញ្ចូលខេត្តតំបន់ឆ្នេរ (ភាគច្រើននៃទិន្នន័យ CAS ឆ្នាំ២០២២ បានមកពីការនេសាទមានការពឹងផ្អែកខ្លាំងលើការនេសាទតាមវាលស្រែ)។

ផលនេសាទតាមឧបករណ៍នេសាទ និងតាមទីជម្រក គឺរួមបញ្ចូលតែទិន្នន័យផលនេសាទដែលនេសាទបានដោយប្រើឧបករណ៍នេសាទតែមួយនិង/ឬ នៅទីជម្រកតែមួយប៉ុណ្ណោះ។ របាយការណ៍ផ្នែកនេះមិនបានរាប់បញ្ចូលទិន្នន័យដែលនេសាទបានដោយប្រើឧបករណ៍នេសាទច្រើន ឬបាននេសាទនៅទីជម្រកច្រើនជាងមួយឡើយ។ ទម្ងន់ផលនេសាទសម្រាប់ថ្ងៃធ្វើនេសាទតាមទីជម្រកច្រើន គឺមានចំនួន ៣៣៦៤ គីឡូក្រាម (១៩% នៃចំនួនសរុប) ហើយទម្ងន់នៃផលនេសាទសម្រាប់ថ្ងៃធ្វើនេសាទដោយប្រើឧបករណ៍នេសាទច្រើន គឺមានចំនួន ៤៨៩៣ គីឡូក្រាម (២៧,៧% នៃចំនួនសរុប)។

ចំនួនសំណាកបច្ចុប្បន្នមានការគ្របដណ្តប់ល្អសម្រាប់តំបន់ទំនាបលិចទឹក និងទន្លេសាប ប៉ុន្តែមានការផ្តោតស្ទើរតែទាំងស្រុងលើគ្រួសារអ្នកនេសាទដែលរស់នៅតាមមាត់ទន្លេសម្រាប់តំបន់ខ្ពង់រាប ដោយគ្រាន់តែគ្របដណ្តប់តែលើខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ដោយគ្មានការប្រមូលទិន្នន័យពីខេត្តរតនគិរី (ដែលជាតំបន់គ្របដណ្តប់ផ្នែកខ្លះនៃដៃទន្លេសំខាន់ៗទាំងបីភ្ជាប់ទៅទន្លេមេគង្គ) គឺមិនគ្រប់គ្រាន់ឡើយ។ ខេត្តតំបន់ភ្នំ ដូចជាខេត្តមណ្ឌលគិរី និងខេត្តត្បូងឃ្មុំ

ខេត្តក្នុងតំបន់ខ្ពង់រាប និងខេត្តតំបន់ភ្នំផ្សេងទៀត ក៏ត្រូវបានដកចេញពី CAS ផងដែរ សំខាន់គឺដោយសារការនេសាទមានការប្រែប្រួលតាមរដូវកាលនៅតំបន់នេសាទខ្ពស់ៗ រួមនឹងការលំបាកខ្លាំងក្នុងការប្រមូលទិន្នន័យនៅតំបន់ដាច់ស្រយាល។ CAS បច្ចុប្បន្នក៏មិនបានរាប់បញ្ចូលខេត្តតំបន់ឆ្នេរឡើយ។ ទាំងនេះមានន័យថា របកគំហើញនៃរបាយការណ៍នេះមិនទាន់បានគ្របដណ្តប់ផលនេសាទទឹកសាបបានពេញលេញនៅឡើយ។

លើសពីនេះទៀត ស្ថានភាពរបាយសំណាកបច្ចុប្បន្ន និងបម្រែបម្រួលខ្ពស់នៃទិន្នន័យ បង្ហាញថាការប៉ាន់ប្រមាណផលនេសាទសម្រាប់ខេត្តមួយចំនួនមិនមានភាពត្រឹមត្រូវតាមបែបស្ថិតិឡើយ ទោះជាការគណនាធ្វើឡើងដោយធ្វើការបូកទិន្នន័យបញ្ចូលគ្នាតាមត្រីមាសក៏ដោយ។

**តារាងទី១៣.** ទំហំសំណាកដែលបានគ្របដណ្តប់សម្រាប់ការប៉ាន់ប្រមាណផលនេសាទ និងសមត្ថភាពនេសាទតាមខេត្តគោលដៅ ដោយផ្អែកលើទិន្នន័យ CAS ឆ្នាំ២០២២

| ខេត្ត | តំបន់នេសាទ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
|---|---|---|---|---|
| កំពង់ចាម | ទំលាបលិចទឹក | ២០០ | ៨៣ | ៧៧ |
| កណ្តាល | ទំលាបលិចទឹក | ៦៨ | ៣៥ | ៥២ |
| ព្រៃវែង | ទំលាបលិចទឹក | ១១២ | ៥៩ | ៦៥ |
| តាកែវ | ទំលាបលិចទឹក | ៦៧ | ៥១ | ៤២ |
| បន្ទាយមានជ័យ | ទន្លេសាប | ១០០ | | |
| កំពង់ស្ពឺ | ទន្លេសាប | ៧៣ | ៤៧ | ៣៥ |
| កំពង់ធំ | ទន្លេសាប | ៣៧១ | ៣០ | ២៩ |
| បាត់ដំបង | ទន្លេសាប | ២៥ | ៣៥ | ២៧ |
| ពោធិសាត់ | ទន្លេសាប | ១៦ | ៣៤ | ៥៨ |
| សៀមរាប | ទន្លេសាប | ៧៩ | ៤១ | ៤២ |
| ក្រចេះ | ខ្ពង់រាប | ៩៧ | ៥១ | ៤៩ |
| ស្ទឹងត្រែង | ខ្ពង់រាប | ២០០ | ៣៣ | ៩៤ |
| កំពត | ឆ្នេរ | ៦៨ | | |
| **ការប៉ាន់ប្រមាណទំហំសំណាកសរុប** | | ១២០៨ | ៤៩៩ | ៥៧០ |
| **មធ្យម** | | NA | **៤៥** | **៥២** |

ដើម្បីបង្កើនភាពត្រឹមត្រូវនៃស្ថិតិ និងកាត់បន្ថយតម្លៃកម្រិតលម្អៀង ៩% អោយទាបជាង ២៥% ទំហំសំណាកតម្រូវដោយផ្អែកលើបម្រែបម្រួលទិន្នន័យនៅឆ្នាំ២០២២ និងគ្រួសារអ្នកនេសាទសកម្ម (តារាងទី១៣)។ ដោយសារមានបម្រែបម្រួលទិន្នន័យខ្ពស់ខ្លាំងសម្រាប់ត្រីមាសទី១ រួមជាមួយនឹងសមាមាត្រនៃគ្រួសារនេសាទសកម្មទាប នោះការបង្កើនទំហំសណាកដល់ចំនួន ១២០០គ្រួសារអ្នកនេសាទ គឺជាការចាំបាច់សម្រាប់ការប៉ាន់ប្រមាណប្រចាំត្រីមាសតាមខេត្ត សម្រាប់បណ្តាខេត្តគោលដៅដែលបានអនុវត្តកន្លងមកថ្មីៗនេះ។ ទំហំសំណាកទាប និងខ្ពស់បំផុត ដែលបានគណនា គឺអាស្រ័យលើបម្រែបម្រួលទិន្នន័យ ដែលបានសង្កេតឃើញកន្លងមក ហើយមានការប្រែប្រួលទៅតាមខេត្ត។ សម្រាប់ត្រីមាសទី៣ និងទី៤ ទំហំសំណាកជាមធ្យម គឺស្ថិតនៅចន្លោះពី ៤៥-៦០ គ្រួសារតាមខេត្តជារៀងរាល់ខែ។ នេះមានន័យថា ដើម្បីអោយ CAS គ្រប់ដណ្តប់ថ្នាក់ជាតិពេញលេញ ជាការចាំបាច់ត្រូវ ប្រមូលទិន្នន័យពី ៣-៤

ភូមិក្នុងខេត្តនីមួយៗ ដោយមាន ១៥គ្រួសារអ្នកនេសាទ ក្នុង១ភូមិ ដូចនេះ ទំហំសំណាកសរុបត្រូវស្ថិតក្នុងចន្លោះ ១០៨០-១៤៤០ គ្រួសារ។

ជម្រើសមួយផ្សេងទៀត ខេត្តដែលមិនមែនជាខេត្តនេសាទស្នូល រួមមានតំបន់ឆ្នេរនិងតំបន់ភ្នំ អាចមានខេត្ត តំណាងត្រឹមតែ ១ ឬ ២ខេត្ត សម្រាប់តំបន់នីមួយៗ។ តាមជម្រើសនេះ ទំហំសំណាកសរុបនឹងមានរវាង ៧៦៥ និង ១១៤០ សំណាក (តារាងទី១៤)។ តាមការប៉ាន់ប្រមាណនេះ គឺតំណាងឱ្យការកើនឡើង ២-៣ ដងនៃទំហំសំណាកឆ្នាំ ២០២២ ហើយវាអាចជាការពិបាកក្នុងការអនុវត្ត។

ជំនួសឱ្យការធ្វើសំណាកសារឡើងវិញ ជាអនុសាសន៍ CAS ដាក់បញ្ចូលភូមិគោលដៅ ដែលត្រូវបានដកចេញពីមុន ពីព្រោះការជ្រើសរើសសំណាកចៃដន្យថ្មីត្រូវការពេលវេលាច្រើន។ ជាការសមហេតុផលផងដែរ ក្នុងការការប្រើប្រាស់សំណាកគ្រួសារចៃដន្យ ដែលត្រូវបានប្រើប្រាស់ដោយគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ របស់ធនាគារពិភពលោកដំណាក់កាលទី៣ សម្រាប់តំបន់ខ្ពង់រាប ដែលមានឯកសារពិពណ៌នាលម្អិត។

ការយកទំហំសំណាកអប្បបរិមា និងសំណាកសមស្របដែលបានគណនាខាងលើ ហើយរក្សាទំហំសំណាកនេះបានរហូត គឺចាំបាច់ត្រូវមានការសហការជាមួយខណ្ឌរដ្ឋបាលជលផលខេត្តគោលដៅនីមួយៗក្នុងការប្រមូលទិន្នន័យ។ គោលបំណងមួយក្នុងចំណោមគោលបំណងនៃការវាយតម្លៃផលនេសាទ តាមបែបវិទ្យាសាស្រ្ត គឺដើម្បីកែលម្អការប៉ាន់ប្រមាណផលនេសាទត្រីនៅតាមខេត្ត។ ការបង្កើនកិច្ចសហប្រតិបត្តិការជាមួយខណ្ឌរដ្ឋបាលជលផល នឹងអាចឱ្យការប្រមូលទិន្នន័យបានកាន់តែច្រើន ការចំណាយទាប ដោយចៀសវាងបង្កើនបន្ទុកការងារដល់មន្ត្រីរដ្ឋបាលជលផល/IFReDI។ ការកែតម្រូវលើវិសាលភាពគ្របដណ្តប់ គឺផ្អែកលើទិសដៅប្រើប្រាស់ទិន្នន័យទទួលបានពីការអនុវត្ត CAS ជាពិសេសទាក់ទងនឹងរបៀបដែល CAS នឹងរួមចំណែកដល់ស្ថិតិជលផលជាតិ និងប្រើប្រាស់មេរៀនដែលទទួលបានពីការអនុវត្ត CAS ដើម្បីធ្វើការកែលម្អ និងកំណត់គម្រូនៃការប្រមូលទិន្នន័យមួយ ដែលនឹងត្រូវទទួលខុសត្រូវដោយខណ្ឌរដ្ឋបាលជលផល។

IFReDI ចាំបាច់ត្រូវធ្វើការត្រួតពិនិត្យដិតដល់នូវភាពត្រឹមត្រូវនៃស្ថិតិប្រចាំខែ ដើម្បីវាយតម្លៃថាតើ មានភាពចាំបាច់ក្នុងការផ្លាស់ប្តូរការរៀបចំសំណាក ដែរឬទេ។ ការរៀបចំរបាយការណ៍ស្ថិតិប្រចាំខែនៅពេលមានទិន្នន័យប្រមូលបានដោយប្រើមូលដ្ឋានទិន្នន័យតាមអនឡាញ ដែលបង្កើតឡើង ដោយមានការគាំទ្រពី FAO នឹងជួយសម្រួលដល់ការវាយតម្លៃការប្រមូលទិន្នន័យ។

**តារាងទី១៤**. ទំហំសំណាកសម្រាប់ការអនុវត្ត CAS ឆ្នាំ២០២៣

| តំបន់នេសាទ | ខេត្ត | ខេត្ត CAS | អប្បរមា (៤៥ គ្រួសារ) | ខ្ពស់បំផុត (៦០គ្រួសារ) | សំណាក ឆ្នាំ២០២២ |
|---|---|---|---|---|---|
| ទំនាបលិចទឹក | ៥ | ៥ | ២២៥ | ៣០០ | ១១៥ |
| ទន្លេសាប | ៧ | ៧ | ៣១៥ | ៤២០ | ១៣៥ |
| ខ្ពង់រាប | ៣ | ៣ | ១៣៥ | ១៨០ | ១០០ |
| ភ្នំ | ៥ | ១ | ៤៥ | ១២០ | 0 |
| ឆ្នេរ | ៤ | ១ | ៤៥ | ១២០ | ៤០ |
| **សរុប** | **២៤** | **១៧** | **៧៦៥** | **១១៤០** | **៣៩០** |

ខេត្តតំបន់ភ្នំអាចគ្របដណ្តប់បានតែពេលខ្លះក្នុង១ឆ្នាំ នៅតែពេលណា ដែលគេរំពឹងថានឹងមានការនេសាទ ជួនកាលរាល់បីខែម្តងទើបមានការនេសាទ។

ការសម្រេចចិត្តទាក់ទងនឹងចំនួនគ្រួសារអ្នកនេសាទ និងការញែកសំណាក ចាំបាច់ត្រូវពិនិត្យឡើងវិញ។ ចំណុច ចំនួន ០២ ត្រូវបន្ថែមទៀត៖

១) បច្ចុប្បន្ន ខេត្តកំពង់ស្ពឺ ត្រូវបានដាក់បញ្ចូលក្នុងតំបន់ទន្លេសាប ប៉ុន្តែការនេសាទមានលក្ខណៈ ស្រដៀងគ្នានឹង ខេត្តទំនាបលិចទឹក។ ដូចគ្នាដែរ ខេត្តកំពង់ចាមត្រូវបានបញ្ចូលទៅក្នុងតំបន់ទំនាបលិចទឹក ទោះបីជាខេត្តនេះជា ផ្នែកមួយនៃអធិការដ្ឋានរដ្ឋបាលជលផលមេគង្គក៏ដោយ ដោយហេតុថា ជលផលនៅខេត្តនេះមានលក្ខណៈស្រ ដៀងនឹងតំបន់ទំនាបលិចទឹក និង

២) ការប៉ាន់ប្រមាណផលនេសាទសរុប គឺត្រូវផ្អែកលើចំនួនគ្រួសារជនបទ ដែលទទួលបានពីជំរឿនប្រជាជនឆ្នាំ ២០១៩ និងសមាមាត្រនៃគ្រួសារនេសាទ ដែលទទួលបានពីការសម្ភាសន៍ HSI។

*IFReDI ចាំបាច់ផ្តួចផ្តើមអោយមានការពិភាក្សាដើម្បីសម្រេចចិត្តលើ៖*

- គោលបំណង និងអនាគតនៃ CAS ដែលទាក់ទងនឹងការកែលម្អស្ថិតិផ្លូវការសម្រាប់ជលផលទឹកសាប ជាពិសេស ទាក់ទងនឹងសេចក្តីព្រាងផែនទីបង្ហាញផ្លូវ និងក្រុមការងារគ្រប់គ្រងស្ថិតិ និងព័ត៌មាន (WSIM) ដែលទើបបង្កើត នៅរដ្ឋបាលជលផល
- វិធីសាស្ត្រនៃការកែលម្អទម្រង់នៃការប្រមូលទិន្នន័យ ប្រសិនបើផ្ទេរការងារប្រមូលទិន្នន័យទៅ ខណ្ឌរដ្ឋបាលជល ផល ឧ. ដូចជាអាចដកចេញនូវសូចនាករ ដែលមិនរួមចំណែកដល់ការប៉ាន់ប្រមាណផលនេសាទតាមប្រភេទ និងសមត្ថភាពនេសាទ៖ ការប្រើប្រាស់ឧបករណ៍ ការប្រើប្រាស់ផលនេសាទ ទីជម្រក និងការចូលរួមពាក់ព័ន្ធនៃ សមាជិកគ្រួសារ
- ការពង្រីកការគ្របដណ្តប់ទៅខេត្តតំបន់ឆ្នេរ និងតំបន់ភ្នំ ព្រមទាំងវិធីសាស្ត្រអនុវត្តការប្រមូលទិន្នន័យនៅតំបន់ ទាំងនេះ ដោយមិនអោយលើសពីធនធានមន្ត្រីដ៏មានកម្រិតរបស់ រដ្ឋបាលជលផល ឬIFReDI ឧ. ដោយកៀរគរ មន្ត្រីខណ្ឌរដ្ឋបាលជលផលជួយគាំទ្រដល់ការប្រមូលទិន្នន័យ
- តម្រូវការសម្រាប់ការប៉ាន់ប្រមាណផលនេសាទសរុបប្រចាំខែ និងស្ថិតិផ្សេងទៀត តាមខេត្ត (ដែលមានផលប៉ះ ពាល់ដល់ទំហំ និងរបាយសំណាក) និង
- ការញែកសំណាក ដើម្បីធ្វើការសម្រេចចិត្តថា តើរបាយនៃសំណាក និងចំនួនភូមិគោលដៅ សមស្របដែរទេ ឧ. ធ្វើការពិនិត្យតភូមិគោលដៅតាមដងទន្លេ និងតាមតំបន់ដីគោក។

*ការវិភាគទិន្នន័យ ដែល IFReDI បានអនុវត្តកន្លងមក មានបញ្ហាមួយចំនួនចាំបាច់ត្រូវលាតត្រដាងឡើង ជាពិសេស៖*

១). ការកត់ត្រាប្រភេទ ដោយមិនមានបញ្ជាក់ជាក់លាក់។ ចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពឧបករណ៍ប្រមូលទិន្នន័យ Kobo ដើម្បីទប់ស្កាត់ការបញ្ចូលទិន្នន័យផលនេសាទ និងសមត្ថភាពនេសាទ ដោយមិនបានបញ្ជាក់ប្រភេទ ឧបករណ៍ ឬ ទីជម្រក។

២). បច្ចុប្បន្នកំពុងប្រើប្រាស់កូដប្រភេទ ចំនួន២ បញ្ចូលគ្នា កូដ MRC និងកូដ HCI ចំនុចនេះរួមបញ្ចូលកូដដូចគ្នា ដែលសំដៅទៅលើប្រភេទផ្សេងៗគ្នា អាស្រ័យលើប្រភេទកូដ (MRC ឬ HCI) ដែលគេបានប្រើ ឧ. Species ID 23, MRC: *Probarbus jullieni* និង HCI: *Hemibagrus spilopterus* ឬ SpeciesID 131, MRC*: Oxyeleotris*

៣). ចាំបាច់ត្រូវពិនិត្យ វិធីបញ្ចូលលេខកូដប្រភេទឡើងវិញ ដោយសារមានទិន្នន័យមានកំណត់ត្រាជាច្រើនមិនមានឈ្មោះ ឬលេខកូដប្រភេទ ដែលបន្ទាប់មកត្រូវបានកែតម្រូវដោយដៃ ដោយផ្អែកលើឧបករណ៍ ទីតាំង និងទីជម្រក ដើម្បីបន្ថែមទិន្នន័យដែលបាត់បង់។ កំណត់ត្រាដែលមានការបាត់បង់ទិន្នន័យគន្លឹះ ចាំបាច់ត្រូវដាក់ការកំណត់សម្គាល់ក្នុងអំឡុងពេលប្រមូលទិន្នន័យ ដើម្បីកាត់បន្ថយការងារសម្អាតទិន្នន័យជាអប្បបរមា។

៤). ចាំបាច់ត្រូវធ្វើការពិនិត្យបញ្ជីទីជម្រក និងឧបករណ៍នេសាទឡើងវិញ ដើម្បីធានាថាមិនមានការបញ្ចូលប្រភេទដែលមានលក្ខណៈមិនច្បាស់លាស់។

៥). ទម្ងន់នៃការប្រើប្រាស់ផលនេសាទ និងផលនេសាទតាមប្រភេទសរុប ជារឿយៗមិនត្រូវគ្នា ចំនុចនេះចាំបាច់ត្រូវកត់សម្គាល់នៅក្នុងឧបករណ៍បញ្ចូលទិន្នន័យ Kobo នៅកំឡុងពេលប្រមូលទិន្នន័យ ដូច្នេះបញ្ហានេះអាចត្រូវបានដោះស្រាយនៅកំឡុងពេលប្រមូលទិន្នន័យ។

៦). ទម្រង់ប្រមូលទិន្នន័យ និងលំដាប់នៃទិន្នន័យ ចាំបាច់ត្រូវកែតម្រូវ ដោយផ្អែកលើការពិនិត្យឡើងវិញ និងទិន្នន័យចាំបាច់សម្រាប់ IFReDI។

ដោយយោងទៅនឹងទិដ្ឋភាពនៃការវិវត្តន៍ CAS ការរៀបចំសំណាក ការគ្របដណ្តប់ និងការញែកសំណាក ចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពសៀវភៅណែនាំការតាមដានវាយតម្លៃផលនេសាទ ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរទាំងនេះ។ IFReDI ត្រូវការស្វែងរកជំនួយបច្ចេកទេសពី FAO CAPFISH ដើម្បីដោះស្រាយបញ្ហា ដែលបានកំណត់ខាងលើ ហើយធ្វើការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងសហប្រតិបត្តិការអន្តរជាតិ (DPFIC) ដើម្បីឯកភាពគ្នាលើរបៀបនៃការយកលទ្ធផលដែលទទួលបានពី CAS ទៅប្រើដើម្បីកែលម្អស្ថិតិជលផលជាតិ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំ[illegible] ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២៣

ហត្ថលេខា

**បណ្ឌិត ហេង គង់**

**បានឃើញ**

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល និងជាប្រធានកម្មវិធី CAPFISH-Capture**

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំ[illegible] ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២៣

**ពុំ សុវចរ**

ឧបសម្ព័ន្ធ១. របាយខេត្តតាមតំបន់នេសាទ និងចំនួនគ្រួសារនេសាទ

| ខេត្ត | តំបន់នេសាទ | ជំរឿនប្រជាជនឆ្នាំ២០១៩ | | | គ្រួសារនេសាទជនបទ | កំណត់សម្គាល់ |
|---|---|---|---|---|---|---|
| | | សរុប | ទីក្រុង | ជនបទ | | |
| បន្ទាយមានជ័យ | ទន្លេសាប | ១៨៩.៥៨៨ | ៦៨.៦៦០ | ១២០.៩២៨ | ៥៨.៤១៦ | |
| បាត់ដំបង | ទន្លេសាប | ២២៧.២៣៧ | ៤៥.៥៥៦ | ១៨១.៦៨១ | ៨៧.៧៦៣ | |
| កំពង់ចាម | ទំនាបលិចទឹក | ២១៧.១៩៧ | ៣០.៣៨៦ | ១៨៦.៨១១ | ១៤៨.២៦៣ | បញ្ចូលក្នុងអធិការដ្ឋានមេគង្គ |
| កំពង់ឆ្នាំង | ទន្លេសាប | ១២៦.២៩៩ | ២៨.៥២៣ | ៩៧.៧៧៦ | ៤៧.២៣២ | |
| កំពង់ស្ពឺ | ទន្លេសាប | ១៩៥.៨៨២ | ១១៤.៣៨០ | ៨១.៥០២ | ៣៩.៣៧១ | បញ្ចូលក្នុងតំបន់ទន្លេសាប ទោះជាជលផលស្រដៀងនឹងតំបន់ទំនាបលិចទឹក |
| កំពង់ធំ | ទន្លេសាប | ១៦០.៧៦៦ | ១៦.១១៨ | ១៤៤.៦៤៨ | ៦៩.៨៧៤ | |
| កំពត | ឆ្នេរ | ១៤៣.៤០២ | ១៣.២៥៨ | ១៣០.១៤៤ | ៤៩.៩៧៥ | |
| កណ្ដាល | ទំនាបលិចទឹក | ២៦៥.៨០៣ | ១៧០.៧៨២ | ៩៥.០២១ | ៧៥.៤១៣ | |
| កោះកុង | ឆ្នេរ | ២៨.០២៧ | ១២.៣៥៩ | ១៥.៦៦៨ | ៦.០១៧ | |
| ក្រចេះ | ខ្ពង់រាប | ៨៦.១៧៦ | ៩.២៩៧ | ៧៦.៨៧៩ | ៥១.៤១៦ | |
| បណ្ដូលគីរី | ភ្នំ | ២០.៤០៩ | ៧.៥០០ | ១២.៩០៩ | ៤.៣៦០ | |
| ភ្នំពេញ | | ៤៩៩.២៩៩ | ៤៩៩.២៩៩ | | | មិនរាប់បញ្ចូលគ្រួសារ ទាំងអស់រស់នៅទីក្រុង |
| ព្រះវិហារ | ភ្នំ | ៥៦.៧១៣ | ៥.៦៥០ | ៥១.០៦៣ | ១៧.២៤៦ | |
| ព្រៃវែង | ទំនាបលិចទឹក | ២៦៦.៩៣៤ | ១៤.១៦៨ | ២៥២.៧៦៦ | ២០០.៦០៨ | |
| ពោធិសាត់ | ទន្លេសាប | ១០៣.៨៦២ | ១៧.៦២៤ | ៨៦.២៣៨ | ៤១.៦៥៨ | |
| រតនគីរី | ខ្ពង់រាប | ៤៩.៧៤១ | ៦.៨៧៧ | ៤២.៨៦៤ | ២៨.៦៦៧ | |
| សៀមរាប | ទន្លេសាប | ២២៤.៦៧២ | ៦៧.៨៤៥ | ១៥៦.៨២៧ | ៧៥.៧៥៧ | |
| ព្រះសីហនុ | ឆ្នេរ | ៤៧.៣៨១ | ៣៤.០៦០ | ១៣.៣២១ | ៥.១១៥ | |
| ស្វាយរៀង | ទំនាបលិចទឹក | ១៣២.៤៩២ | ៣៧.២៨៥ | ៩៥.២០៧ | ៧៥.៥៦១ | |
| តាកែវ | ទំនាបលិចទឹក | ២០៨.៦៩៨ | ៦២.៨៥៦ | ១៤៥.៨៤២ | ១១៥.៧៤៨ | |
| ឧត្តរមានជ័យ | ភ្នំ | ៦០.៨៨៦ | ១៩.៨២៦ | ៤១.០៦០ | ១៣.៨៦៨ | |
| កែប | ឆ្នេរ | ៩.៦០៥ | ៧.៧១៤ | ១.៨៩១ | ៧២៦ | មិនរាប់បញ្ចូលដោយសារគ្រួសារទាំងអស់នេសាទនៅសមុទ្រ |
| ប៉ៃលិន | ភ្នំ | ១៧.១៧៧ | ១៣.០៥០ | ៤.១២៧ | ១.៣៩៤ | |
| ត្បូងឃ្មុំ | ភ្នំ | ១៧៨.៩៤២ | ១៥.៦៦៧ | ១៦៣.២៧៥ | ៥៥.១៩៦ | |
| ស្ទឹងត្រែង | ខ្ពង់រាប | ៣៥.៨៣៣ | ៩.៧៦១ | ២៦.០៧២ | ១៧.៤៣៧ | |
| **សរុប** | | | | | ១.២៨៧.០៣១ | |

ឧបសម្ព័ន្ធ២. ការប៉ាន់ប្រមាណផលនេសាទតាមខេត្ត ដោយផ្អែកលើទិន្នន័យប្រចាំត្រីមាស

**ត្រីមាសទី២: មេសា-មិថុនា**

| ខេត្ត | តំបន់នេសាទ | % គ្រួសារសកម្ម | ផលនេសាទប្រចាំខែតាមគ្រួសារ (គ.ក្រ) | SD | ε% | សរុប (តោន) |
|---|---|---|---|---|---|---|
| កំពង់ចាម | ទំនាបលិចទឹក | ២៨% | ៨៤,៦២ | ២៦,៤៦ | ៣០,៨% | ៣.៥១៧ |
| កណ្ដាល | ទំនាបលិចទឹក | ៣៨% | ៥១,៨៩ | ១១,១០ | ១៥,៧% | ១.៤៩០ |
| ព្រៃវែង | ទំនាបលិចទឹក | ២៦% | ៥១,៥៥ | ១១,៥៤ | ២២,៧% | ២.៦៨១ |
| តាកែវ | ទំនាបលិចទឹក | ៤២% | ៧៣,២៥ | ១៦,២៨ | ១៦,៩% | ៣.៥២៨ |
| បន្ទាយមានជ័យ | ទន្លេសាប | ៤០% | ១២៧,៩៣ | ៣៣,៥១ | ៤២,០% | ២.៩៨៩ |
| កំពង់ស្ពឺ | ទន្លេសាប | ៣៧% | ៣០,៤៥ | ៦,៥៤ | ២០,៤% | ៤៤៤ |
| កំពង់ធំ | ទន្លេសាប | ១៨% | ៧០,៦៧ | ២៤,៣០ | ៣៣,៩% | ៩០៤ |
| បាត់ដំបង | ទន្លេសាប | ៩០% | ៥៤,១១ | ១០,៦៦ | ១២,១% | ៤.២៥៦ |
| ពោធិសាត់ | ទន្លេសាប | ៨២% | ៩០,៥៥ | ១៣,៨៤ | ៩,៩% | ៣.០៩០ |
| សៀមរាប | ទន្លេសាប | ៤០% | ៣៣,១៩ | ៧,៧៧ | ២៨,១% | ១.០១៤ |
| ក្រចេះ | ខ្ពង់រាប | ២៤% | ៤៨,១១ | ៩,៦៨ | ២១,៣% | ៥៨៦ |
| ស្ទឹងត្រែង | ខ្ពង់រាប | ៤៤% | ៧១,៦១ | ៩,៥៥ | ១១,៥% | ៥៤៥ |
| កំពត | ឆ្នេរ | ៤១% | ៤៥,៤៣ | ៨,៤២ | ២០,០% | ៩៣៨ |
| ផលនេសាទមធ្យមប្រចាំខែប៉ាន់ប្រមាណសរុប (តោន) | | | | | | ២៥.៩៨២ |
| ផលនេសាទសរុបប៉ាន់ប្រមាណប្រចាំត្រីមាស (តោន) | | | | | | ៧៧.៩៤៦ |

**ត្រីមាសទី៣: កក្កដា-កញ្ញា**

| ខេត្ត | តំបន់នេសាទ | % គ្រួសារសកម្ម | ផលនេសាទប្រចាំខែតាមគ្រួសារ (គ.ក្រ) | SD | ε% | សរុប (តោន) |
|---|---|---|---|---|---|---|
| កំពង់ចាម | ទំនាបលិចទឹក | ៣០% | ៦៤,៩៥ | ១៣,៥៩ | ២៥,៦% | ២.៨៨៩ |
| កណ្ដាល | ទំនាបលិចទឹក | ៥១% | ៤១,៩៣ | ៧,៤១ | ១៦,៦% | ១.៦២០ |
| ព្រៃវែង | ទំនាបលិចទឹក | ៤៤% | ១៦,៥៥ | ៣,៤៨ | ២០,០% | ១.៤៧៥ |
| តាកែវ | ទំនាបលិចទឹក | ៥៣% | ៣០,១៥ | ៦,៥៨ | ១៩,១% | ១.៨៤៣ |
| កំពង់ស្ពឺ | ទន្លេសាប | ៧៦% | ២៨,៧៦ | ៧,២០ | ១៨,៣% | ៨៦២ |
| កំពង់ធំ | ទន្លេសាប | ៥៧% | ៣១,០៥ | ៥,៣០ | ១៤,៤% | ១.២៤៣ |
| បាត់ដំបង | ទន្លេសាប | ៧១% | ៥៥,៩៨ | ១១,៧០ | ១៦,៣% | ៣.៤៩៣ |
| ពោធិសាត់ | ទន្លេសាប | ៦១% | ៧៧,៤៣ | ១៤,៨៣ | ១៥,៦% | ១.៩៧៩ |
| សៀមរាប | ទន្លេសាប | ៦៩% | ៣៦,៥៦ | ៧,៩៩ | ១៧,២% | ១.៩១៣ |
| ក្រចេះ | ខ្ពង់រាប | ៧៣% | ៦៦,០៥ | ១៦,៧១ | ១៦,២% | ២.៤៧០ |
| ស្ទឹងត្រែង | ខ្ពង់រាប | ៥៧% | ៤១,០៦ | ៧,៥២ | ១០,៥% | ៤០៩ |
| ផលនេសាទមធ្យមប្រចាំខែប៉ាន់ប្រមាណសរុប (តោន) | | | | | | ២០.១៩៦ |
| ផលនេសាទសរុបប៉ាន់ប្រមាណប្រចាំត្រីមាស (តោន) | | | | | | ៦០.៥៨៨ |

**ត្រីមាសទី៤: តុលា-ធ្នូ**

| ខេត្ត | តំបន់នេសាទ | % គ្រួសារសកម្ម | ផលនេសាទប្រចាំខែតាមគ្រួសារ (គ.ក្រ) | SD | ε% | សរុប (តោន) |
|---|---|---|---|---|---|---|
| កំពង់ចាម | ទំនាបលិចទឹក | ៣៤% | ៨៤,៨១ | ១៨,១៤ | ២៤,២% | ៤.២៤២ |
| កណ្ដាល | ទំនាបលិចទឹក | ៦៩% | ៥៦,៣៩ | ១៤,០៤ | ២០,១% | ២.៩២៤ |
| ព្រៃវែង | ទំនាបលិចទឹក | ៤៩% | ១៩,៦៤ | ៤,៦១ | ២១,២% | ១.៩២៦ |
| តាកែវ | ទំនាបលិចទឹក | ៥៩% | ៤១,៨២ | ៨,៧៤ | ១៧,២% | ២.៨៥០ |
| កំពង់ស្ពឺ | ទន្លេសាប | ៦៦% | ២០,៨៧ | ៤,១៨ | ១៥,៦% | ៥៤៥ |
| កំពង់ធំ | ទន្លេសាប | ៦១% | ១៤៩,២១ | ២៦,១២ | ១៧,០% | ៦.៣៩០ |
| បាត់ដំបង | ទន្លេសាប | ៨៤% | ១៤១,៣៨ | ២៨,០៣ | ១៤,២% | ១០.៤៦៤ |
| ពោធិសាត់ | ទន្លេសាប | ៥០% | ៣៦,១៩ | ៨,០៦ | ២៨,៥% | ៧៥៤ |
| សៀមរាប | ទន្លេសាប | ៦៥% | ៦៩,០១ | ១៥,០០ | ១៧,៣% | ៣.៣៨៦ |
| ក្រចេះ | ខ្ពង់រាប | ៦១% | ៦១,៥៤ | ១៣,៩៥ | ១៥,០% | ១.៩២២ |
| ស្ទឹងត្រែង | ខ្ពង់រាប | ៤៦% | ៣៩,៨១ | ១០,៨៤ | ១៨,០% | ៣១៦ |
| ផលនេសាទមធ្យមប្រចាំខែប៉ាន់ប្រមាណសរុប (តោន) | | | | | | ៣៥.៧២០ |
| ផលនេសាទសរុបប៉ាន់ប្រមាណប្រចាំត្រីមាស (តោន) | | | | | | ១០៧.១៥៩ |
| | | | | | | |
| ការប៉ាន់ប្រមាណរយៈពេល ៩ខែ (តោន) | | | | | | ២៤៥.៦៩៣ |
| ការប៉ាន់ប្រមាណរយៈពេល ១២ខែ ឆ្នាំ២០២២ (តោន) | | | | | | ៣២៧.៥៩១ |